## សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
## មហាវិទ្យាល័យអប់រំ

កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន កម្រិតបរិញ្ញាបត្រ

# ការពិនិត្យតាមដាន
# និងការវាយតម្លៃគ្រឹះស្ថានសិក្សា



សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
មហាវិទ្យាល័យអប់រំ

កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀនកម្រិតបរិញ្ញាបត្រ
ប្រភពហិរញ្ញប្បទាន៖ គម្រោងកែលម្អការអប់រំចំណេះទូទៅ



## កញ្ចប់សមត្ថភាពទី១
## ចំណេះដឹងឯកទេសបរិញ្ញាបត្រ









# មុខវិជ្ជាៈ
# ការប្រើប្រាស់កុំព្យូទ័រ និងបច្ចេកវិទ្យាឌីជីថលសម្រាប់ការអប់រំ

កញ្ចប់សមត្ថភាពទី ៣

ហ្វឹកហាត់កម្មសិក្សា និងការអនុវត្តជាក់ស្តែង

## ការពណ៌នាអំពីមុខវិជ្ជា

មុខវិជ្ជានេះត្រូវបានរៀបចំឡើងដើម្បីឲ្យនិស្សិតស្គាល់និងតាមដានដំណើរនៃការផ្លាស់ប្តូរ លើផ្លូវកំណែទម្រង់ការអប់រំ ដោយពិនិត្យទៅលើលំហូរនៃការពិនិត្យតាមដានខែ ពិនិត្យឡើងវិញត្រីមាស និងវាយតម្លៃចុងឆ្នាំ ទៅលើក្រុមគោលដៅឆ្នាំរបស់សាលារៀន ក្រុមគោលដៅថ្នាក់រៀន១ថ្នាក់ ក្រុមគោលដៅសិក្សាសិស្ស១នាក់ ដោយរួមបញ្ចូលទាំងការពិនិត្យតាមដានគម្រោងផងដែរ ។

**លទ្ធផលសិក្សារំពឹងទុកៈ**

*ក្រោយពីបញ្ចប់ការសិក្សាមុខវិជ្ជានេះដោយជោគជ័យអ្នកសិក្សានឹងៈ*

១. លទ្ធផលសិក្សារំពឹងទុកទី ១ៈ បរិយាយបានពីការវិវត្តន៍នៃការអប់រំពីអតីតកាលដល់បច្ចុប្បន្ន
២. លទ្ធផលសិក្សារំពឹងទុកទី ២ៈ អាចពិនិត្យ តាមដានការវិវត្តនៃការអប់រំក្រុមគោលដៅបាន
៣. លទ្ធផលសិក្សារំពឹងទុកទី ៣ៈ អាចវាយតម្លៃលទ្ធផលសិក្សារំពឹងទុក
៤. លទ្ធផលសិក្សារំពឹងទុកទី ៤ៈ អាចផ្សព្វផ្សាយលទ្ធផលសិក្សាទៅតាមគោលដៅជាក់លាក់
៥. លទ្ធផលសិក្សារំពឹងទុកទី ៥ៈ អាចផ្តល់ព័ត៌មានត្រឡប់ចំពោះលទ្ធផលសិក្សាបាន

**របាយតម្លៃសិក្សា**

*ដើម្បីបំពេញគ្រប់លក្ខខណ្ឌបញ្ចប់ការសិក្សាមុខវិជ្ជានេះ អ្នកសិក្សាត្រូវ*

១. វត្តមានចូលសិក្សា ១០%
២. ការចូលរួមសកម្មភាពសិក្សា ២០%
៣. ការវាយតម្លៃកំឡុងពេលសិក្សា ៣០%
៤. ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សា ៤០%

# អារម្ភកថា

ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦ នៃរដ្ឋសភា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក្នុងចំណុចចតុកោណទី១ បានកំណត់យក "ការអភិវឌ្ឍធនធានមនុស្ស" មុំទី១ជាវិស័យអាទិភាព។ សាកលវិទ្យាល័យ-ភូមិន្ទភ្នំពេញដើរតួនាទីយ៉ាងសំខាន់ជាចំណែកមួយនៃការកែទម្រង់វិស័យអប់រំក្នុងការស្តារប្រព័ន្ធអប់រំជាតិឡើងវិញ តាមរយៈការផលិតអ្នកអប់រំដែលមានគុណភាពខ្ពស់។

នៅដើមអាណត្តិទី៦នេះ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវយុទ្ធសាស្ត្រកំណែទម្រង់ វិស័យអប់រំ ២០១៨-២០២៣ ដែលមានចក្ខុវិស័យ "កសាង និងអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើនផ្នែកចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន"។ ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក៏បានលើកឡើងពីតួនាទីយ៉ាងសំខាន់របស់គ្រូបង្រៀនក្នុងវិស័យអប់រំ និងសង្គមជាតិ ដោយបញ្ជាក់ថា "គុណភាពគ្រូ ជាគុណភាពមូលធនមនុស្ស សម្រាប់ ការអភិវឌ្ឍប្រកបដោយចីរភាព" ដែលប្រែក្លាយប្រទេសមានប្រាក់ចំណូល មធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងប្រទេសអភិវឌ្ឍន៍ក្នុងឆ្នាំ២០៥០។

ដើម្បីឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រ និងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា រួមជាមួយនឹងកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា សាកលវិទ្យាល័យភូមិន្ទភ្នំពេញបានទទួលភារកិច្ចបន្ថែមទៀត តាមរយៈការអនុវត្តគម្រោងកែលម្អការអប់រំនៅកម្រិតមធ្យមសិក្សា និងបន្តអនុវត្តគម្រោងកែលម្អការអប់រំចំណេះទូទៅរយៈពេលបួនឆ្នាំបន្តទៀត ចាប់ពីឆ្នាំ២០២២-២០២៦។ ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សាបានដឹកនាំ និងផ្តល់អនុសាសន៍យ៉ាងច្រើន ដែលធ្វើឱ្យគម្រោងប្រព្រឹត្តទៅដោយរលូន និង ជោគជ័យ។

គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សារៀបចំឡើង ដើម្បីលើកកម្ពស់គុណវុឌ្ឍិគ្រូឯកទេសលើមុខវិជ្ជាគោល៦ តាមគ្រឹះស្ថានមធ្យមសិក្សាគោលដៅ។ សាកលវិទ្យាល័យភូមិន្ទភ្នំពេញទទួលបណ្តុះបណ្តាលក្របខណ្ឌកម្មវិធីកម្រិតបរិញ្ញាបត្រអប់រំដល់នាយកសាលារៀន និងគ្រូឯកទេសដែលពុំទាន់មានសញ្ញាបត្របរិញ្ញាបត្រ ឬមានសញ្ញាបត្រខុសឯកទេសនៅតាមគ្រឹះស្ថានមធ្យមសិក្សាចំនួន១០០ នៅក្នុងគោលដៅគម្រោងនៅប្រទេសកម្ពុជា។ ដើម្បីពង្រីកវិសាលភាពនៃកំណែទម្រង់អប់រំ គម្រោងកែលម្អការអប់រំចំណេះទូទៅ ដែលប្រើប្រាស់យុទ្ធសាស្ត្រសហគមន៍សាលារៀនជាយុទ្ធសាស្ត្រស្នូលក្នុងការអនុវត្ត បានលេចរូបរាងឡើងក្នុងគោលបំណងបណ្តុះបណ្តាលនាយកសាលា និងគ្រូបង្រៀនចំនួនប្រមាណ ១៧០០០ នាក់ ដែលមកពី ១៧០០សាលា ក្នុងអនុវិស័យបី រួមមាន កុមារតូច បឋមសិក្សា និងមធ្យមសិក្សា។ មហាវិទ្យាល័យអប់រំក៏ត្រូវសហការផងដែរ ជាមួយស្ថាប័ន បណ្តុះបណ្តាលគ្រូទាំងអស់ ដើម្បីឈានទៅបង្កើតស្តង់ដាគុណភាពរួមមួយក្នុងការអប់រំគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលាឱ្យបានទូលំទូលាយ។ ដើម្បីឈានទៅសម្រេចបានការអនុវត្តគម្រោងថ្មីនេះ មហាវិទ្យាល័យត្រូវមានយុទ្ធសាស្ត្ររយៈពេលវែងមួយ សម្រាប់ឆ្នាំ ២០២១-២០៣០ ដើម្បីជាមគ្គុទេសបង្ហាញផ្លូវ។

សៀវភៅសិក្សាគោលយុទ្ធសាស្ត្រសហគមន៍សាលារៀននេះ បានរៀបចំឡើងជាការឆ្លើយតបជាមួយតម្រូវការដែលអ្នកសិក្សាជានាយក និងគ្រូបង្រៀនក្នុងគម្រោងកែលម្អការអប់រំចំណេះទូទៅដើម្បីធ្វើការស្វ័យសិក្សាលើខ្លឹមសារសំខាន់ៗ នៃយុទ្ធសាស្ត្រសហគមន៍សាលារៀន ដែលការស្វ័យសិក្សានេះបានភ្ជាប់មកជាមួយសំណួរស្វ័យសិក្សា ដែល

បញ្ជាក់ពីកម្រិតយល់ដឹងពីខ្លឹមសារគោលនីមួយៗនៃយុទ្ធសាស្ត្រសហគមន៍សាលារៀន។ តាមរយៈសៀវភៅសិក្សាគោលនេះ អ្នកសិក្សាក្នុងគម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) និងគ្រឹះស្ថានបណ្តុះបណ្តាលឯទៀតអាចយកជាប្រយោជន៍ក្នុងការអនុវត្តកំណែទម្រង់សាលារៀន ដែលយកសហគមន៍ជាធនធានគោល ដើម្បីអភិវឌ្ឍន៍សាលារៀនឱ្យឈានទៅរកសាលារៀនជាប់ស្តង់ដាសហគមន៍សាលារៀន។

ទន្ទឹមនឹងនេះ វាជាឯកសារដែលឆ្លុះបញ្ចាំងពីមេរៀន បទពិសោធន៍នៃការអនុវត្ត និងផលសម្រេចជាក់ស្តែង និងជាឯកសាររស់ដែលមានលក្ខណៈបើកទូលាយឱ្យមានការកែលម្អបន្តផ្អែកលើការរៀនពីការអនុវត្ត ដែលនាំមកនូវលទ្ធផលវិជ្ជមាន។ ឯកសារនេះមានខ្លឹមសារ ដែលជាអត្ថប្រយោជន៍សម្រាប់ប្រើប្រាស់ក្នុងពេល ដែលបានអនុវត្តន៍កន្លងមក និងបន្តប្រើប្រាស់ក្នុងពេលបច្ចុប្បន្ន ហើយអាចនឹងប្រើប្រាស់សម្រាប់អនាគត ឬអាចនឹងកែសម្រួលបន្ថែមឱ្យសមស្របតាមកាលៈទេសៈ និងល្បឿននៃការអភិវឌ្ឍក្នុងសង្គមជាតិ។

សាកលវិទ្យាល័យភូមិន្ទភ្នំពេញមានជំនឿយ៉ាងមុតមាំ ក្នុងការរៀបចំក្របខណ្ឌកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ក្រោមគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សាពិតជាដើរតួនាទីយ៉ាងសំខាន់ និងឆ្លើយតបទៅនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការសាងធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និងក្រមសីលធម៌។ យើងនឹងបន្តការខិតខំប្រឹងប្រែងក្នុងការអនុវត្តគម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) ឱ្យបានកាន់តែប្រសើរជាមួយនឹងសៀវភៅសិក្សាគោលយុទ្ធសាស្ត្រសហគមន៍សាលារៀន និងឧត្តមានុវត្តន៍ផ្សេងៗដែលបានចងក្រង។

ខ្ញុំសូមថ្លែងអំណរគុណ និងសូមកោតសរសើរចំពោះក្រុមការងារដែលបានខិតខំកសាងក្របខណ្ឌកម្មវិធីឱ្យទទួលបានលទ្ធផលល្អ។

ថ្ងៃ ពុធ ១៤ រោច ខែ អាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កក្កដា ឆ្នាំ២០២២

**សាកលវិទ្យាធិការ**

**បណ្ឌិត ជេត ជាលី**

## រចនាសម្ព័ន្ធកម្មវិធីសិក្សា

កម្មវិធីសិក្សាកម្រិតបរិញ្ញាបត្រអប់រំមានចំនួន ៦៣ ក្រេឌីត ដោយបញ្ចូលការសិក្សាលើមុខវិជ្ជាសិក្សា ការចូលរួមវគ្គសិក្ខាសាលាជាបន្តបន្ទាប់ ការអនុវត្តផ្ទាល់ និងការចងក្រងរបាយការណ៍ស្រាវជ្រាវ។ ដោយសារអ្នកសិក្សាក្នុង កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនបានបំពេញគុណវុឌ្ឍិចំនួន ៦៣ ក្រេឌីត។ (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៣៦ ក្រេឌីត) (២)ចំណេះដឹងវិធីសាស្ត្រដឹកនាំ និងការគ្រប់គ្រងតាមសាលារៀន (១២ (+៣) ក្រេឌីត) (៣)ហ្វឹកហាត់កម្មសិក្សា និងការអនុវត្តជាក់ស្តែង (១២ ក្រេឌីត)។

ការចូលរួមសិក្ខាសាលាតម្រូវឱ្យនិស្សិត/អ្នកសិក្សារៀនបន្ថែម និងចែករំលែកបទពិសោធអំពីការអនុវត្តការងារនៅសាលារៀន។ ការអនុវត្តផ្ទាល់ គឺភ្ជាប់និស្សិត/អ្នកសិក្សាទៅនឹងការបំពេញកិច្ចការអនុវត្ត ដើម្បីចងក្រងបទពិសោធនៃការបំពេញការងារផ្អែកលើលទ្ធផល។ របាយការណ៍ស្រាវជ្រាវតម្រូវឱ្យនិស្សិត/អ្នកសិក្សាចងក្រងនូវបទពិសោធដែលអនុវត្តការងារប្រកបដោយផលសម្រេច។

| កញ្ចប់សមត្ថភាព | ចំនួនមុខវិជ្ជា | ចំនួនក្រេឌីត |
|---|---|---|
| (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៦០%) | ១២ មុខវិជ្ជា | ៣៦ |
| (២)ចំណេះដឹងវិធីសាស្ត្រដឹកនាំ និងការគ្រប់គ្រងតាមសាលារៀន (២០%) | ៤(+១) មុខវិជ្ជា | ១២ (+៣) |
| (៣)ហ្វឹកហាត់កម្មសិក្សានិងការអនុវត្តជាក់ស្តែង (២០%) | ៣ មុខវិជ្ជា | ១២ |
| សរុប | ២០ | ៦៣ |

## ក្របខណ្ឌកម្មវិធីសិក្សាបរិញ្ញាបត្រអប់រំ

មុខវិជ្ជាសិក្សាសម្រាប់កម្រិតបរិញ្ញាបត្រអប់រំនេះនឹងជួយឱ្យនិស្សិត/អ្នកសិក្សាបំពេញកញ្ចប់សមត្ថភាពដូចខាងក្រោមដើម្បីឆ្លើយតបនឹងលទ្ធផលសិក្សាកម្មវិធីអប់រំហើយឱ្យនិស្សិត/អ្នកសិក្សាមានសមត្ថភាពសម្រាប់បំពេញការងារប្រកបដោយវិជ្ជាជីវៈ។

| កញ្ចប់សមត្ថភាព | មុខវិជ្ជាសិក្សា | ចំនួនក្រេឌីត |
|---|---|---|
| (១)ចំណេះដឹងឯកទេស កម្រិតបរិញ្ញាបត្រ ៣៦ ក្រេឌីត(៦០%) | ចិត្តវិទ្យាអប់រំ | ៣ |
| | មូលដ្ឋានគ្រឹះអប់រំ | ៣ |
| | ការប្រើប្រាស់កុំព្យូទ័រ និងបច្ចេកវិទ្យាឌីជីថលសម្រាប់ការអប់រំ | ៣ |
| | ភាសាអង់គ្លេសសម្រាប់ការអប់រំ | ៣ |
| | មូលដ្ឋានគ្រឹះនៃវង្វាយតម្លៃអប់រំ | ៣ |
| | មូលដ្ឋានគ្រឹះការស្រាវជ្រាវប្រតិបត្តិ | ៣ |
| | វិធីសាស្ត្រស្រាវជ្រាវ | ៣ |
| | ការគ្រប់គ្រងការរៀន និងបង្រៀន | ៣ |

| | | |
|---|---|---|
| | ភាពជាអ្នកដឹកនាំក្នុងការគ្រប់គ្រងសាលារៀននិងរដ្ឋបាលសាលារៀន | ៣ |
| | ការសិក្សាពហុវិន័យនៅមធ្យមសិក្សា | ៣ |
| | ការអប់រំអំពីបម្រែបម្រួលអាកាសធាតុនៅមធ្យមសិក្សា | ៣ |
| | បញ្ញាតិ និងគោលការណ៍ការអនុវត្តការគ្រប់គ្រងតាមសាលារៀន | ៣ |
| (២)ចំណេះដឹងវិធីសាស្ត្រដឹកនាំ និងការគ្រប់គ្រងតាមសាលារៀន ១២ (+៣) ក្រេឌីត (២០%) | ការគ្រប់គ្រង និងការវិភាគទិន្នន័យអប់រំ | ៣ |
| | ការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ការអប់រំ | ៣ |
| | ការគ្រប់គ្រង និងការអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំ | ៣ |
| | ដំណើរការ ការគ្រប់គ្រងសាលារៀននៅមធ្យមសិក្សា | ៣ |
| | ការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀនសម្រាប់មធ្យមសិក្សា | ៣ |
| (៣)ហ្វឹកហាត់កម្មសិក្សា និងការអនុវត្តជាក់ស្តែង ១២ ក្រឌីត (២០%) | ការពិនិត្យតាមដាន និងការវាយតម្លៃគ្រឹះស្ថានសិក្សា | ៣ |
| | ការធ្វើអធិការផ្ទៃក្នុងតាមសាលារៀន | ៣ |
| | ការសរសេររបាយការណ៍ស្រាវជ្រាវ | ៦ |
| សរុប | | ៦៣ |

## លំហូរបង្រៀន និងរៀន

**លំហូរបង្រៀននិងរៀន ១មេរៀន ឬកិច្ចការមួយ រួមជាមួយបំណិនមួយ និងចរិយាមួយ**



## ស្តង់ដាស្តង់ដាគណៈគ្រប់គ្រងសាលារៀននៃយុទ្ធសាស្ត្រសហគមន៍សាលារៀន

**ស្តង់ដាទី១ និង ៤** សាលារៀនដំណើរការសម្រាប់ផលសម្រេចការអប់រំនិងការសិក្សារបស់សិស្ស និងដំណើរការរដ្ឋបាល និងប្រតិបត្តិការសហគមន៍សាលារៀន។ក្នុងការបណ្តុះបណ្តាលលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀនទាំងអស់ត្រូវបានណែនាំឱ្យអនុវត្តកិច្ចការដូចតទៅ៖

| | |
|---|---|
| ១ | កែលម្អការសិក្សារៀនសូត្ររបស់សិស្សពីថ្នាក់ទី៧ ដល់ទី១២ នាំឱ្យសិស្សអាចទទួលបានកម្រិតល្អ និងល្អប្រសើរលើមុខវិជ្ជាគោល។ |
| ២ | ផ្តោតការសិក្សារបស់សិស្សលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាជាអទិភាព ពិសេសនៅមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា។ |
| ៣ | អនុវត្តអនុសាសន៍របាយការណ៍ការគ្រប់គ្រងហិរញ្ញវត្ថុ និងសវនកម្ម។ |
| ៤ | ធ្វើឱ្យការសិក្សាមានភាពបន្សុីគ្នារវាងសាលាមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាដើម្បីឈានឆ្ពោះទៅឧត្តមសិក្សា។ |
| ៥ | បង្កើនប្រសិទ្ធផល និងកំណត់មុខសញ្ញាប្រើប្រាស់ធនធាន ដោយផ្តោតលើអទិភាពរបស់សាលារៀនដែលមានមូលដ្ឋានលើយុទ្ធសាស្ត្រ វប្បធម៌ និងគុណតម្លៃ។ |

## ការវាយតម្លៃលើការសិក្សា

ការវាយតម្លៃលើការសិក្សារបស់និស្សិត/អ្នកសិក្សាគឺផ្តោតលើលទ្ធផលសិក្សាជាគោល។ ការវាយតម្លៃលើការសិក្សាមានបីដំណាក់កាលធំៗ គឺ (១) ការវាយតម្លៃលើការសិក្សាមុខវិជ្ជា (២) ការវាយតម្លៃលើការសរសេររបាយការណ៍ស្រាវជ្រាវ និង (៣) ការវាយតម្លៃសរុបដោយពិនិត្យលើការបំពេញគ្រប់លក្ខខណ្ឌសម្រាប់បញ្ចប់ការសិក្សា។

## គោលការណ៍វាយតម្លៃ

គោលការណ៍រួមសម្រាប់ការវាយតម្លៃលើការសិក្សារបស់និស្សិត/អ្នកសិក្សាមានដូចតទៅ៖

១) និស្សិត/អ្នកសិក្សាតម្រូវឱ្យមានវត្តមានក្នុងការសិក្សាតាមមុខវិជ្ជានីមួយៗ មិនតិចជាង៧០%។ ក្នុងករណីអ្នកសិក្សាមានវត្តមានតិចជាង៧០% នឹងមិនត្រូវបានអនុញ្ញាតឱ្យប្រឡងបញ្ចប់មុខវិជ្ជានោះទេ។

២) ក្នុងករណីដែលនិស្សិត/អ្នកសិក្សាធ្លាក់មុខវិជ្ជាណាមួយក្នុងឆមាស នឹងមិនអនុញ្ញាតឱ្យបន្តការសិក្សាទៅឆ្នាំបន្ទាប់ និងប្រឡងបញ្ចប់ឡើយ។

៣) និស្សិត/អ្នកសិក្សាទាំងអស់ត្រូវធ្វើកិច្ចការស្រាវជ្រាវសំខាន់ៗតាមមុខវិជ្ជានីមួយៗ និងប្រគល់ជូនគ្រូឧទ្ទេសតាមមុខវិជ្ជាដែលបានកំណត់។

៤) និស្សិត/អ្នកសិក្សាត្រូវប្រឡងបញ្ចប់ការសិក្សាដែលធ្វើឡើងបន្ទាប់ពីចប់ឆមាសនីមួយៗ តាមការកំណត់ក្នុងកម្មវិធីសិក្សា។

៥) និស្សិត/អ្នកសិក្សាត្រូវចងក្រងឯកសារវឌ្ឍនភាពនៃកិច្ចការស្នូលរួមមានការហាត់ការ និងកម្មសិក្សាដែលផ្តោតលើ (ក) សកម្មភាពប្រតិបត្តិ (ខ) លទ្ធផលដែលសម្រេចបាន និង (គ) ការឆ្លុះបញ្ចាំង និងមេរៀនបទពិសោធន៍។

៦) និស្សិត/អ្នកសិក្សាត្រូវតែជាប់មធ្យមភាគនៃការសិក្សាមុខវិជ្ជានិងការធ្វើកម្មសិក្សា ដើម្បីទទួលការអនុញ្ញាតឱ្យការពាររបាយការណ៍ស្រាវជ្រាវ។

## ការផ្តល់ពិន្ទុ និងប្រព័ន្ធចំណាត់ថ្នាក់

និស្សិត/អ្នកសិក្សាអាចទទួលពិន្ទុចាប់ពី 00 ដល់ 100 ទៅតាមការវាយតម្លៃផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់ក្នុងការសិក្សាមុខវិជ្ជា ការបំពេញកម្មសិក្សា និងការសរសេរនិងការការពាររបាយការណ៍។ ពិន្ទុដែលជាប់ត្រូវចាប់ផ្តើមពីមធ្យមភាគពិន្ទុ 50% ឬពិន្ទុនិទ្ទេស 2.00 ឡើងទៅ។

ពិន្ទុគឺកំណត់ពី 00.00 ដល់ 100 (មធ្យមភាគនៃពិន្ទុនិទ្ទេសសរុប ឬ Grade Point Average – GPA)។ រូបមន្តគណនារកមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) គឺមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) ស្មើផលបូកសរុបរវាងផលគុណនៃពិន្ទុនិទ្ទេស (Grade Point – P) និងតម្លៃក្រេឌីតដែលត្រូវយកនៃមុខវិជ្ជានីមួយៗ (Attempted Credit Value – C) ចែកនឹងផលបូកសរុបនៃតម្លៃក្រេឌីតដែលត្រូវយកគ្រប់មុខវិជ្ជា។

ប្រព័ន្ធចំណាត់ថ្នាក់កម្មវិធី គឺផ្អែកទៅលើតម្លៃនៃពិន្ទុអតិបរមា 100% និង 50% នៃពិន្ទុអប្បបរមា។ ប្រព័ន្ធដាក់ពិន្ទុនេះ ត្រូវបានបកប្រែទៅជា "ពិន្ទុជានិទ្ទេស" និង "ពិន្ទុជាតម្លៃលេខ" ដូចដែលពិពណ៌នាដូចខាងក្រោម៖

| ពិន្ទុជាភាគរយ% | និទ្ទេស | ពិន្ទុនិទ្ទេស | មូលវិចារណ៍ |
|---|---|---|---|
| 85%-100% | A | 4.00 | ល្អប្រសើរ |
| 80%-84% | B+ | 3.50 | ល្អណាស់ |
| 70%-79% | B | 3.00 | ល្អ |
| 65%-69% | C+ | 2.50 | ល្អបង្គួរ |
| 50%-64% | C | 2.00 | មធ្យម |
| <49% | F | 1.50 | ធ្លាក់ |

## គោលការណ៍ប្រតិបត្តិ

ដើម្បីធានានូវការផ្តល់សេវាអប់រំប្រកបដោយគុណភាព និងភាពស័ក្តិសិទ្ធ មហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញអនុវត្តតាមគោលការណ៍ បទបញ្ញត្តិ និងបទដ្ឋានគតិយុត្តិរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងគោលការណ៍ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ជាមួយគ្នានេះដែរ និស្សិត/អ្នកសិក្សាម្នាក់ៗ ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងឈរលើស្មារតីស្មោះត្រង់ ទទួលខុសត្រូវខ្ពស់ និងភាពម្ចាស់ការ និងគោលការណ៍សុចរិតភាពនៃការសិក្សា។ សម្រាប់គោលការណ៍សុចរិតភាពនៃការសិក្សា និស្សិត/អ្នកសិក្សាម្នាក់ៗ ត្រូវបានវាយតម្លៃលើចំណុចសំខាន់ៗដូចខាងក្រោម៖

**ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយា**

ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់និស្សិត/អ្នកសិក្សាម្នាក់ៗ ត្រូវបានប្រមូលផ្តុំលើការគោរពវិន័យចាត់តាំង ការមករៀនទៀងទាត់ ការយកចិត្តទុកដាក់ក្នុងការសិក្សា ការខិតខំស្រាវជ្រាវ ការអនុវត្ត ភារកិច្ច និងស្មារតីសាមគ្គីភាពនៅក្នុងថ្នាក់ ក្នុងសាលារៀន និងក្រៅសាលារៀន។ ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់និស្សិតម្នាក់ៗ ត្រូវបានធ្វើឡើងតាមរយៈយោបល់ឯកភាពពីមតិភាគច្រើនដាច់ខាតរបស់ក្រុមប្រឹក្សាវិន័យ ដោយផ្អែកលើលក្ខណសម្បត្តិជាក់ស្តែងរបស់និស្សិត/អ្នកសិក្សាម្នាក់ៗ និងបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

**ការក្លែងបន្លំឯកសារ**

និស្សិត/អ្នកសិក្សាដែលក្លែងបន្លំឯកសារ នឹងត្រូវលុបឈ្មោះចេញពីបញ្ជីនិស្សិតដោយស្វ័យប្រវត្តិ ព្រមទាំងទទួលទោសតាមច្បាប់ជាធរមាន។ និស្សិតត្រូវចាំថា ការលួចចម្លងស្នាដៃ ការលួចកម្មសិទ្ធិបញ្ញា និងគំនិតរបស់អ្នកដទៃគឺជាបទល្មើសសិក្សាធ្ងន់ធ្ងរដែលអាចឈានដល់ការបញ្ឈប់និស្សិតដែលប្រព្រឹត្តបទល្មើសពីកម្មវិធី។ និស្សិត/អ្នកសិក្សានឹងត្រូវធ្លាក់ជាស្ថាពរ បើនិស្សិត/អ្នកសិក្សារូបណាចម្លងដោយផ្ទាល់ពីនិស្សិតដទៃទៀត ឬប្រភពផ្សេងៗ ឬការប្រើសម្ភារៈ ឬឯកសារផ្សេងទៀត ដែលមិនត្រូវបានអនុញ្ញាតក្នុងការប្រឡង។

**របាយការណ៍/កិច្ចការស្រាវជ្រាវ**

និស្សិត/អ្នកសិក្សាត្រូវបង្ហាញនូវសុចរិតភាពនៃការស្រាវជ្រាវរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួនចាប់តាំងពីពេលចូលរៀនរហូតដល់ចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល។ រាល់សំណេរការងារសិក្សាទាំងអស់ មិនត្រូវដកស្រង់គំនិត សរសេរ ឬចម្លងស្នាដៃផ្សេងៗរបស់អ្នកដទៃមកធ្វើជាគំនិតជាស្នាដៃ ឬជាកម្មសិទ្ធិរបស់ខ្លួនដោយគ្មានការបញ្ជាក់ពីប្រភពច្បាស់លាស់នៃឯកសារយោង ឯកសារពិគ្រោះ ឬការអនុញ្ញាតពីម្ចាស់ប្រភព។

ក្នុងករណីរកឃើញមានការលួចចម្លងស្នាដៃអ្នកដទៃ និស្សិត/អ្នកសិក្សានឹងត្រូវប្រឈមមុខចំពោះក្រុមប្រឹក្សា បច្ចេកទេស និងក្រុមប្រឹក្សាវិន័យរបស់មហាវិទ្យាល័យអប់រំ ឬសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយត្រូវទទួលពិន័យឱ្យរៀនត្រួតថ្នាក់ ឬអាចត្រូវបញ្ឈប់ពីកម្មវិធីដោយគ្មានសំណងប្រាក់សិក្សាដែលបានបង់រួចហើយទេ និងមិនមានការចេញលិខិតស្នាមបញ្ជាក់ការសិក្សាអ្វីដែរ។

**សំគាល់៖** កម្មវិធីបណ្តុះបណ្តាលសូមរក្សាសិទ្ធិក្នុងការកែប្រែការអនុវត្តជាក់ស្តែងដើម្បីឆ្លើយតបវឌ្ឍនភាពការរៀននិងបង្រៀន សមត្ថភាពរៀន និងអនុវត្តជាក់ស្តែង ស្ថានភាពរៀននិងបង្រៀនជាក់ស្តែង ដើម្បីសម្រេចបានលទ្ធផលសិក្សាល្អបំផុត និងសម្រេចស្តង់ដាសហគមន៍សាលារៀននៃគម្រោង GEIP។

# ដំណើរនៃការផ្លាស់ប្តូរ លើផ្លូវកំណែទម្រង់
# តើអ្នកកំពុងនៅកម្រិតណា ?

77

១. **មិនបានគិតៈ** មិនអើពើដឹង មិនរវល់ពីបញ្ហា គិតពីចរិយាខ្លួនឯងឡើងវិញ វិភាគពីចរិយា និងហានិភ័យដែលនឹងកើតមាន

២. **ចាប់ផ្តើមគិតៈ** មានយោបល់ផ្ទុយគ្នា ចិតអារម្មណ៍ប្រឆាំងគ្នា ថ្លឹងថ្លែងពីអ្វីត្រូវនិងមិនត្រូវ កំណត់នូវភាពរួចស្រេចសម្រាប់កំណែទម្រង់ និងស្វែងរកឧបសគ្គដែលអាចនឹងកើតមាន

៣. **ការរៀបចំសម្រាប់កំណែទម្រង់ៈ** អនុវត្តកិច្ចការ១ឲ្យបានជោគជ័យ ប្រមូលព័ត៌មានពីភាពជោគជ័យ សរសេរគោលបំណងរបស់អ្នក រៀបចំផែនការសកម្មភាព សរសេរឃ្លាដែលនាំអ្នកមានចិត្តធ្វើការ(វប្បធម៌និងគុណតម្លៃ)

៤. **អនុវត្តផែនការសកម្មភាពៈ** ធ្វើសកម្មភាពផ្តោតលើគោលបំណង ផ្តល់រង្វាន់ដល់ភាពជោគជ័យ ស្វែងរកការគាំទ្រសង្គម

៥. **ការថែរក្សាការអនុវត្តកំណែទម្រង់ៈ** ថែរក្សាឲ្យបាននូវចរិយាកំណែទម្រង់ ជៀសវាងនូវចរិយានាំបំផ្លាញ កំណត់និងអនុវត្តចរិយាទប់ទល់នឹងចរិយាបំផ្លាញ ចងចាំនូវការផ្តល់រង្វាន់ដល់ខ្លួនអ្នក

៦. **ទប់ទល់ការលាប់ឡើងវិញនៃចរិយាដំណាក់ទីមួយៈ** ការខកចិត្ត ការអោចិត្ត ខ្លាចបរាជ័យ ស្វែងរកកត្តានាំមានការលាប់ឡើងវិញ ស្វែងស្គាល់ឧបសគ្គរាំងភាពជោគជ័យ កំណត់ឡើងវិញនូវគោលបំណងនិងការប្តេជ្ញាចិត្តកំណែទម្រង់របស់អ្នក

78

# ដំណើរនៃការពិនិត្យតាមដាន

79

## លំហូរនៃការពិនិត្យតាមដានខែ ពិនិត្យឡើងវិញត្រីមាស និងវាយតម្លៃចុងឆ្នាំ




80

## បរិបទអតីតកាល

- បើគ្មានផែនការផ្តោតលើលទ្ធផល ដែលបញ្ជាក់ដោយក្រុមគោលដៅឆ្នាំ តើអាចធ្វើការវាយតម្លៃ ផ្តោតលើលទ្ធផលបានទេ
- បើគ្មានផែនការលទ្ធផលត្រីមាស តើអាចធ្វើការពិនិត្យឡើងវិញ នូវការរីកចម្រើនលទ្ធផលប្រចាំត្រីមាសដែរឬទេ ហើយតើអាចឈានទៅសម្រេចលទ្ធផលជាក្រុមគោលដៅប្រចាំឆ្នាំដែរឬទេ
- បើអនុវត្តកិច្ចការមួយ ដើម្បីតែអនុវត្តកិច្ចការមួយ ដោយមិនដឹងថាត្រូវឬខុស តើអាចធ្វើការពិនិត្យតាមដានបានទេ ហើយតើអាចឈានទៅការកែតម្រូវ ការអនុវត្តកិច្ចការដដែលលើកក្រោយបានត្រូវដែរឬទេ
- ហើយបើការអនុវត្តមានបរិបទដូចខាងលើ តើសិស្សអាចមានសមត្ថភាពតាមទាន់តម្រូវការសង្គម និងទីផ្សារក្នុងប្រទេសនិងសកលលោកបានទេ ហើយប្រសិទ្ធិភាពនៃការចំណាយលុយតើយ៉ាងណាវិញ

81

## បរិបទបច្ចុប្បន្នសម្រាប់អនាគត

- ការពិនិត្យតាមដាន ជាការពិនិត្យលើការអនុវត្តសកម្មភាពនៅសប្តាហ៍ និងខែកន្លង និងការគ្រោងអនុវត្តសកម្មភាពនៅសប្តាហ៍និងខែបន្ទាប់
- ការពិនិត្យឡើងវិញ ជាការពិនិត្យការសម្រេចលទ្ធផលជាក្រុមគោលដៅ ចុងត្រីមាស ជាមួយការគិតពីទំនោរទៅសម្រេចក្រុមគោលដៅនៅត្រីមាសបន្ទាប់
- ការវាយតម្លៃ ជាការពិនិត្យការសម្រេចលទ្ធផល ជាក្រុមគោលដៅ ចុងឆ្នាំ
- ការពិនិត្យនីមួយៗ ត្រូវស្វែងរកបញ្ហាជាក់លាក់ និងមូលហេតុនាំមានបញ្ហា ព្រមទាំងកំណត់សកម្មភាពដោះស្រាយ អ្នកអនុវត្ត និងពេលវេលាត្រូវអនុវត្តចប់

82

## ឧបសគ្គ និងការរាំងស្ទះ នាំជោគជ័យ ឬបរាជ័យ ទាក់ទងនឹងបុគ្គលខ្លួនឯង

- *ឧបសគ្គ៖ មិនអើពើដឹង ប្រឆាំងមិនឲ្យធ្វើ រវល់ការងារច្រើនពេក មិនមែនជាការងារស្មុល មិនដឹងនូវអ្វីត្រូវដឹង ខ្លាចគ្រោះថ្នាក់ មិនសង្ឃឹមថាអាចធ្វើបាន ប៉ុណ្ណឹងបានហើយ*
- *ការរាំងស្កាត់អាចទាក់ទងនឹង៖*
  - *កម្រិតនៃសមត្ថភាពបញ្ហាដោះស្រាយបញ្ហា*
  - *របៀបធ្វើការងារ សមត្ថភាពយល់ដឹងពីការងារ និងផ្ដោតលើការអនុវត្តការងារ*
  - *ចរិយាផ្ដោតលើការងារ និងចរិយាផ្ដោតលើសិលធម៌*
  - *ចរិយារៀនពីរបៀបរៀន រស់ជាមនុស្សពេញលេញ  និងរីករាយ*

83

# *ទិន្នន័យ ព័ត៌មាន ចំណេះដឹង*

84

## ទិន្នន័យ

- ទិន្នន័យៈ ជាលេខចំនួន១ ដូចជាឃ្លា "ចូលរៀន៥០%" មិនអាចប្រាប់ន័យអ្វីទេ
- សូចនាករ១ ស្មើនឹងកិច្ចការ១ ប្រមូលកុមារចូលរៀន
- ធ្វើកិច្ចការ១ នាំផលិតបាននូវ ទិន្នន័យ១
- ធ្វើកិច្ចការ១ត្រឹមត្រូវ នាំឲ្យអ្នកអនុវត្ត ប្តូរអត្តចរិត ចរិយា និងគុណតម្លៃ

85

## ព័ត៌មាន

- ទិន្នន័យ បូកជាមួយ ទិន្នន័យ បង្កើតព័ត៌មានៈ ឃ្លា "កុមារចូលរៀន ៥០%នៅឆ្នាំ២០២២ និង ៦០%នៅឆ្នាំ២០២៣" ឃ្លានេះប្រាប់ន័យពីការចូលរៀន តែវាមិនបានប្រាប់ពីហេតុនិងផលទេ ដូចនេះយើងមិនអាចយល់ន័យបានទេ
- សូចនាករ១ ស្មើនឹងកិច្ចការ១ ធ្វើដដែលនៅឆ្នាំទី២ ពី ប្រមូលកុមារចូលរៀន

86

## ចំណេះដឹង

- ព័ត៌មាន បូកជាមួយ ព័ត៌មាន បង្កើតបានជា ចំណេះដឹង
- ទិន្នន័យពីការចូលរៀនច្រើនឆ្នាំ បូកផ្សំជាមួយ ព័ត៌មាន ពីការប្រមូលស្ថិតិកុមារ ការចុះឈ្មោះចូលរៀន ការចុះតាមផ្ទះ ការជួយផ្តល់សំភារៈរៀនដល់សិស្សក្រីក្រ ។ល។
- ឃ្លាខាងលើនេះ ជាឃ្លាអាចឲ្យយើងយល់បាន ព្រោះវាប្រាប់ពីហេតុនិងផល ដែលនាំឲ្យយើងយល់ពីការកើនឡើងនៃការចូលរៀន
- ប្រសិនបើ ព័ត៌មានពីហេតុនិងផល មិនស៊ីសង្វាក់គ្នា នោះនាំឲ្យយើងអាចវាយតម្លៃថា ព័ត៌មានពីការចូលរៀន មានភាពមិនច្បាស់លាស់

87

## សរុបមកវិញ មានន័យថា

- ទិន្នន័យ និងព័ត៌មាន ដែលផលិត ប្រមូល និងកត់ត្រា គឺ ត្រូវតែពិត នៅពេលវេលា១ត្រូវ
- ទិន្នន័យទាំងអស់ត្រូវតែ ចងក្រងជាព័ត៌មាន សព្វគ្រប់ ដោយជៀសវាងការលាក់បាំងទិន្នន័យឬព័ត៌មានណាមួយ ឬមួយកែច្នៃទិន្នន័យនិងព័ត៌មានពីពិតទៅជាមិនពិត បើធ្វើដូចនេះ នោះរបាយការណ៍នឹងបង្ហាញនូវភាពមិនទទួលខុសត្រូវចំពោះ ប្រជាជន និងរដ្ឋាភិបាលឡើយ
- ទិន្នន័យនិងព័ត៌មានពិត នាំឲ្យយើងអាចវិភាគបាន ហើយនឹងនាំឲ្យយើងអាចស្វែងយល់ ពិភាក្សារកដំណោះស្រាយ ជាកិច្ចការជាក់លាក់បាន

88

# ការពិនិត្យតាមដាននិងវាយតម្លៃ



ខ ការពិនិត្យតាមដានប្រចាំខែ

***ការពិនិត្យតាមដានកម្រិតសិស្សម្នាក់ៗ***

**សិស្សឈ្មោះ ពេជ្រ ចរណៃ ថ្នាក់ទី៧ក ឆ្នាំសិក្សា២០២១ ខែមករា**

***ពិន្ទុ និងនិទ្ទេស៖*** *F:</=50; E=51-60; D=61-70; C=71-79; B=80-89; A=90-100*

| កម្រិតសិក្សាភាសាខ្មែរដើមឆ្នាំសិក្សា | | | | | | | កម្រិតសិក្សាចុងត្រីមាសទី១ | កម្រិតសិក្សាចុងត្រីមាសទី ២ | កម្រិតសិក្សាចុងឆ្នាំ |
|---|---|---|---|---|---|---|---|---|---|
| កម្រិតថ្នាក់ | ១. ស្គាល់ព្យញ្ជនៈនិងស្រៈ | ២. ស្គាល់សំឡេង | ៣. ស្គាល់ពាក្យ | ៤. អានស្ទាត់ | ៥. អានយល់ | កម្រិតសិក្សាដើមឆ្នាំ | | | |
| ទី៨ | | | | | | | | | |
| ទី៧ | | | | FF | FF | FF | F | E | E |
| ទី៥ | | | | EF | | | E | D | D |
| ទី៥ | | | DE | | | | D | C | B |
| ទី៤ | | DE | | | | | C | B | B |
| ទី៣ | BC | | | | | | B | B | B |

គំរូតារាងពិនិត្យតាមដានប្រចាំខែមករា ២០២១

(សម្គាល់៖ យកផែនការបង្រៀនពាក់ខែធ្វើជាតារាងពិនិត្យតាមដានប្រចាំខែនិងត្រីមាស)

ផែនការបង្រៀនពាក់ខែ ថ្នាក់ទី៧ សិស្ស៥០នាក់ ខែមករា ដល់ មីនា ឆ្នាំ២០២១

*ពិន្ទុ និងនិទ្ទេស៖ F:</=50; E=51-60; D=61-70; C=71-79; B=80-89; A=90-100*

| មុខវិជ្ជា | ចំនួន និង % ភាសាខ្មែរ | | | | ចំនួន/% | ចំនួន និង % គណិតវិទ្យា | | | | ចំនួន/% |
|---|---|---|---|---|---|---|---|---|---|---|
| | ទិន្នន័យ មូលដ្ឋាន | ចុងខែ មករា | ចុងខែ កុម្ភៈ | ចុងខែ មីនា | ចុងឆ្នាំ សិក្សា | ទិន្នន័យ មូលដ្ឋាន | ចុងខែ មករា | ចុងខែ កុម្ភៈ | ចុងខែ មីនា | ចុងឆ្នាំ សិក្សា |
| និទ្ទេស A | | 0 | | | | | | | | 2% |
| និទ្ទេស B | | 1 | | | 2% | | | | | 5% |
| និទ្ទេស C | | 1 | | | 5% | | | | | 10% |
| និទ្ទេស D | | 3 | | | 10% | | | | | 10% |
| និទ្ទេស E | | 10 | | | 10% | | | | | 23% |
| និទ្ទេស F | | 35 | | | 23% | | | | | 50% |
| សរុប | 50/100% | | | | 50% | 50/100% | | | | 50/100% |

91

សរុបលទ្ធផលតេស្តស្តង់ដារបស់សាលារៀនតាមមុខវិជ្ជា ដើមឆ្នាំសិក្សា និង ខែមករា ឆ្នាំ ២០២១

កម្រិតពិន្ទុ សិក្សា *F:</=50; E=51-60; D=61-70; C=71-79 ; B=80-89; A=90-100*

| មុខវិជ្ជា | សិស្សសរុប | ចំនួន និង%សិស្ស | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ដើម ខែ | ចុង ខែ | ដើម ខែ | ចុង ខែ | ដើម ខែ | ចុង ខែ | ដើម ខែ | ចុង ខែ | ដើម ខែ | ចុង ខែ | ដើម ខែ | ចុង ខែ |
| ភាសាខ្មែរ | | | | | | | | | | | | | |
| គណិតវិទ្យា | | | | | | | | | | | | | |
| រូបវិទ្យា | | | | | | | | | | | | | |
| គីមីវិទ្យា | | | | | | | | | | | | | |
| ជីវវិទ្យា | | | | | | | | | | | | | |
| ប្រវត្តិវិទ្យា | | | | | | | | | | | | | |
| ភាសាអង់គ្លេស | | | | | | | | | | | | | |
| ព័ត៌មានវិទ្យា | | | | | | | | | | | | | |
| សីលធម៌ ពលរដ្ឋ | | | | | | | | | | | | | |
| ផែនដី និងបរិស្ថានវិទ្យា | | | | | | | | | | | | | |
| ភូមិវិទ្យា | | | | | | | | | | | | | |
| គេហវិទ្យា | | | | | | | | | | | | | |
| អប់រំកាយ កីឡា និងសុខភាព | | | | | | | | | | | | | |
| អប់រំបំណិនជីវិតមូលដ្ឋាន ឬអប់រំវិជ្ជាជីវៈជម្រើស | | | | | | | | | | | | | |
| សរុប | | | | | | | | | | | | | |

92

**បូកសរុបរបាយការណ៍ពីគ្រូទទួលបន្ទុកថ្នាក់ខែមករា ២០២១**

| មុខវិជ្ជាមានការសិក្សាយឺត | ឧបសគ្គ | ការរាំងស្ទាត់ | សកម្មភាពដោះស្រាយ | ផ្សេងៗ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |

*សម្គាល់៖ ឧបសគ្គនិងការរាំងស្ទាត់អាចមកពី គ្រូបង្រៀនខ្វះសមត្ថភាព គ្រូបង្រៀនមិនទទួលខុសត្រូវ គ្រូបង្រៀនមានបញ្ហាសង្គមសេដ្ឋកិច្ចគ្រួសារ សិស្សខ្សោយពេក (មិនចេះអានអក្សរនិងគិតលេខ) ដោយមិនមានការជួយពីគ្រូបង្រៀន សិស្សមិនទទួលខុសត្រូវ សិស្សមានបញ្ហាសង្គមនិងសេដ្ឋកិច្ច ខ្វះការជួយគាំទ្រពីសាលាឬថ្នាក់ក្រោមជាតិឬថ្នាក់ជាតិ។*

93

**របាយការណ៍តាមដានការអនុវត្តផែនការកែលម្អសាលារៀនប្រចាំខែមករា ២០២១**

**ឈ្មោះសាលារៀន** **លេខកូដ** **ឈ្មោះនាយកសាលា**

**លេខទូរស័ព្ទ៖** **ភូមិ** **ឃុំឬសង្កាត់**

**ក្រុង ស្រុក ខណ្ឌ** **រាជធានី ខេត្ត**

| សូចនាករសម្រេចមិនបាន | សកម្មភាពមិនបានអនុវត្តក្នុងខែ | ឧបសគ្គ | ការរាំងស្ទាត់ | សកម្មភាពជាដំណោះស្រាយ |
|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ |
| ស្តង់ដាទី១៖ សាលារៀនមានដំណើរការសម្រេចផលសម្រេចអប់រំនិងការសិក្សារបស់សិស្ស | | | | |
| | | | | |
| ស្តង់ដាទី២៖ ថ្នាក់រៀនមានដំណើរការសម្រាប់ការបង្រៀននិងការសិក្សារបស់សិស្សម្នាក់ៗ | | | | |
| | | | | |

94

| ស្តង់ដាទី៣៖ ភាពជាម្ចាស់របស់សហគមន៍សាលារៀន | | | | |
|---|---|---|---|---|
| | | | | |
| ស្តង់ដាទី៤៖ ដំណើរការប្រតិបត្តិនិងរដ្ឋបាលសាលារៀន | | | | |
| | | | | |
| ស្តង់ដាទី៥៖ គណនេយ្យភាពថ្នាក់ជាតិនិងក្រោមជាតិ | | | | |
| | | | | |

*សម្គាល់៖ នាយកសាលាទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍នេះ ដោយមានការជួយពីនាយករងសាលារៀនទទួលបន្ទុកបច្ចេកទេសសម្រាប់បូកសរុបរបាយការណ៍ពីគ្រូទទួលបន្ទុកថ្នាក់ និងនាយករងសាលារៀនទទួលបន្ទុករដ្ឋបាលក្នុងការរៀបចំរបាយការណ៍ពីការរីកចម្រើនការអនុវត្តផែនការកែលម្អសាលារៀន។*

95

| កំណត់ហេតុប្រជុំប្រចាំខែ ឆ្នាំ២០២៣<br>ថ្ងៃ ខែ ឆ្នាំ ២០២៣ | |
|---|---|
| **ប្រធានបទប្រជុំ** | |
| ១. រាយការណ៍ពីការរីកចម្រើនការអនុវត្តសកម្មភាព និង លទ្ធផលសិក្សារបស់សិស្សនៅក្នុងខែកន្លងមក | |
| ២. ពិភាក្សាពី បញ្ហា ឧបសគ្គ ការរាំងស្ទះ និង សកម្មភាពដោះស្រាយ | |
| ៣. ពិភាក្សាពី សកម្មភាពគ្រោងនៅខែបន្ទាប់ ការត្រៀមអនុវត្តសកម្មភាពនីមួយៗ ពិសេសសកម្មភាពដែលត្រូវមានការជួយនៅក្នុងផ្ទៃក្នុងសាលារៀន ឬពី សាលារៀនមានស្តង់ដា | |
| **ការសម្រេចចិត្ត** | |
| ១. ការអនុវត្តសកម្មភាពជាដំណោះស្រាយបញ្ហាពីខែកន្លងមក<br>ក.<br>ខ.<br>គ. | |
| ២. ការគ្រោងអនុវត្តសកម្មភាពនៅខែបន្ទាប់<br>ក.<br>ខ.<br>គ. | |
| ហត្ថលេខាគណៈកម្មការគ្រប់គ្រងសាលារៀន | ហត្ថលេខានាយកសាលារៀន |

96

ធ ការពិនិត្យតាមដានប្រចាំត្រីមាស និងឆមាស

ការពិនិត្យតាមដានកម្រិតសិស្សម្នាក់ៗ

សិស្សឈ្មោះ ពេជ្រ ចរណៃ ថ្នាក់ទី៧ក ឆ្នាំសិក្សា២០២១ ខែមករា ដល់ខែ មីនា

*ពិន្ទុ និងនិទ្ទេស៖ F:</=50; E=51-60; D=61-70; C=71-79; B=80-89; A=90-100*

| កម្រិតសិក្សាភាសាខ្មែរដើមឆ្នាំសិក្សា | | | | | | | កម្រិតសិក្សាចុងត្រីមាសទី១ | កម្រិតសិក្សាចុងត្រីមាសទី២ | កម្រិតសិក្សាចុងឆ្នាំ |
|---|---|---|---|---|---|---|---|---|---|
| កម្រិតថ្នាក់ | ១. ស្គាល់ព្យញ្ជនៈនិងស្រៈ | ២. ស្គាល់សំឡេង | ៣. ស្គាល់ពាក្យ | ៤. អានស្ទាត់ | ៥. អានយល់ | កម្រិតសិក្សាដើមឆ្នាំ | | | |
| ទី៨ | | | | | | | | | |
| ទី៧ | | | | FF | FF | FF | F | E | E |
| ទី៥ | | | | EF | | | E | D | D |
| ទី៥ | | | DE | | | | D | C | B |
| ទី៤ | | DE | | | | | C | B | B |
| ទី៣ | BC | | | | | | B | B | B |

97

| កម្រិតថ្នាក់ | កម្រិតសិក្សាគណិតវិទ្យាដើមឆ្នាំសិក្សា | | | | | | កម្រិតសិក្សាចុងត្រីមាសទី១ | កម្រិតសិក្សាចុងត្រីមាសទី២ | កម្រិតសិក្សាចុងឆ្នាំ |
|---|---|---|---|---|---|---|---|---|---|
| | □ | □ | □ | □ | □ | □ | | | |
| ទី៨ | | | | | | | | | |
| ទី៧ | | | | | | F□ | F | E | E |
| ទី៦ | | | | | | EF | F | F | D |
| ទី៥ | | | | | DE | | E | D | C |
| ទី៤ | | | | CD | | | D | C | B |
| ទី៣ | | | BC | | | | C | B | B |

98

ការពិនិត្យតាមដានកម្រិតថ្នាក់រៀន

គំរូតារាងពិនិត្យតាមដានប្រចាំត្រីមាសទី១ ខែមករាដល់មីនា ឆ្នាំ ២០២១

(សម្គាល់៖ យកផែនការបង្រៀន៣ខែធ្វើជាតារាងពិនិត្យតាមដានប្រចាំខែនិងត្រីមាស)

ផែនការបង្រៀន៣ខែ ថ្នាក់ទី៧ សិស្ស៥០នាក់ ខែមករាដល់មីនា ឆ្នាំ២០២១

*ពិន្ទុ និងនិន្ទេស៖ F:</=50; E=51-60; D=61-70; C=71-79; B=80-89; A=90-100*

| មុខវិជ្ជា | ចំនួន និង % ភាសាខ្មែរ | | | | ចំនួន/% ចុងឆ្នាំសិក្សា | ចំនួន និង % គណិត វិទ្យា | | | | ចំនួន/% ចុងឆ្នាំសិក្សា |
|---|---|---|---|---|---|---|---|---|---|---|
| | ទិន្នន័យមូលដ្ឋាន | ចុងខែមករា | ចុងខែកុម្ភៈ | ចុងខែមីនា | | ទិន្នន័យមូលដ្ឋាន | ចុងខែមករា | ចុងខែកុម្ភៈ | ចុងខែមីនា | |
| និន្ទេស A | | 0 | | | 2% | | | | | 2% |
| និន្ទេស B | | 1 | | | 5% | | | | | 5% |
| និន្ទេស C | | 1 | | | 10% | | | | | 10% |
| និន្ទេស D | | 3 | | | 10% | | | | | 10% |
| និន្ទេស E | | 10 | | | 23% | | | | | 23% |
| និន្ទេស F | | 35 | | | 50% | | | | | 50% |
| សរុប | 50/100% | | | | | 50/100% | | | | 50/100% |

99

របាយការណ៍សង្ខេប: ប្លុកសរុបរបាយការណ៍ត្រីមាសទី១ ពីគ្រូទទួលបន្ទុកថ្នាក់ខែមករាដល់មីនា ២០២១

| មុខវិជ្ជាមានការសិក្សាយឺត | ឧបសគ្គ | ការរាំងស្ទាត់ | សកម្មភាពដោះស្រាយ | ផ្សេងៗ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

*សម្គាល់៖ ឧបសគ្គនិងការរាំងស្ទាត់អាចមកពី គ្រូបង្រៀនខ្វះសមត្ថភាព គ្រូបង្រៀនមិនទទួលខុសត្រូវ គ្រូបង្រៀនមានបញ្ហាសង្គមសេដ្ឋកិច្ចគ្រួសារ សិស្សខ្សោយពេក(មិនចេះអានអក្សរនិងគិតលេខ) ដោយមិនមានការជួយពីគ្រូបង្រៀន សិស្សមិនទទួលខុសត្រូវ សិស្សមានបញ្ហាសង្គមនិងសេដ្ឋកិច្ច ខ្វះការជួយគាំទ្រពីសាលា ឬ ថ្នាក់ក្រោមជាតិឬថ្នាក់ជាតិ។*

100

**កំណត់ហេតុប្រជុំប្រចាំត្រីមាសទី១ ឆ្នាំ២០២៣**
**ថ្ងៃ ខែ ឆ្នាំ ២០២៣**

**ប្រធានបទប្រជុំ**

១. រាយការណ៍ពីការរីកចម្រើនក្រុមគោលដៅលទ្ធផលសិក្សារបស់សិស្សនៅក្នុងត្រីមាសកន្លងមក

២. ពិភាក្សាពី បញ្ហា ឧបសគ្គ ការរាំងស្ទាត់ និង សកម្មភាពដោះស្រាយ

៣. ពិភាក្សាពី សកម្មភាពគ្រោងនៅត្រីមាសបន្ទាប់ ពិសេសផ្តោតលើការបង្កើនល្បឿនលទ្ធផលសិក្សា ការត្រៀមអនុវត្ត សកម្មភាពនីមួយៗ ពិសេសសកម្មភាពដែលត្រូវមានការជួយនៅក្នុងផ្ទៃក្នុងសាលារៀន ឬពី សាលារៀនមានស្តង់ដា

**ការសម្រេចចិត្ត**

១. ការអនុវត្តសកម្មភាពជាដំណោះស្រាយបញ្ហាពីត្រីមាសកន្លងមក
ក.
ខ.
គ.

២. ការគ្រោងអនុវត្តសកម្មភាពនៅត្រីមាសបន្ទាប់
ក.
ខ.
គ.

ហត្ថលេខាគណៈកម្មការគ្រប់គ្រងសាលារៀន ហត្ថលេខានាយកសាលារៀន

101

**ការរីកចម្រើនការអនុវត្តផែនការបង្រៀនពីរឆ្នាំតាមថ្នាក់ (ចំនួននិងភាគរយ) ឆ្នាំ២០២១**

***ពិន្ទុ និងនិទ្ទេស៖*** *F:</=50; E=51-60; D=61-70; C=71-79; B=80-89; A=90-100*

| | ថ្នាក់ទី៧ក សិស្ស៥០នាក់ | | | | | |
|---|---|---|---|---|---|---|
| | | ចំនួនសិស្ស | ក្រុមគោលដៅ ចុងឆ្នាំទី១ ២០២១ | ផល សម្រេចចុង ឆ្នាំទី១ | ក្រុមគោលដៅ ចុងឆ្នាំទី២ ២០២២ | ក្រុមគោលដៅ ចុងឆ្នាំទី៣ ២០២៣ |
| ១ | ២ | ៣ | ៤ | | ៦ | ៧ |
| ភាសាខ្មែរ | | | | | | |
| | A | | 2% | | 5% | 8% |
| | B | | 5% | | 10% | 15% |
| | C | | 10% | | 14% | 17% |
| | D | | 10% | | 20% | 30% |
| | E | | 23% | | 26% | 20% |
| | F | | 50% | | 25% | 10% |

102

**ផលសម្រេចអប់រំ និងក្រុមគោលដៅសិក្សារៀនស្ទួតបឆ្នាំ**

| លេខ | សូចនាករ | | ឆ្នាំ០ ២០២១ លេខមូលដ្ឋាន | ឆ្នាំទី១ ២០២២ គោលដៅ | សម្រេចបាន ឆ្នាំទី១ ២០២២ | ឆ្នាំទី២ ២០២៣ គោលដៅ | ឆ្នាំទី៣ ២០២៤ គោលដៅ |
|---|---|---|---|---|---|---|---|
| | | | ចំនួន និង % | ចំនួន និង % | | ចំនួន និង % | ចំនួន និង % |
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 |
| 1 | ចូលរៀន ត្រួតថ្នាក់ បោះបង់ និងឡើងថ្នាក់ (ចំនួនសិស្សតាម%កំណត់) | *ចូលរៀន* | TBP | =/>95% | | =/>95% | =/>95% |
| | | *ត្រួតថ្នាក់* | TBP | 0% | | 0% | 0% |
| | | *បោះបង់* | TBP | /3% | | /2% | /1% |
| | | *ឡើងថ្នាក់* | TBP | /100% | | /100% | /100% |
| 2 | ចំនួនសិស្ស(តាម%កំណត់) សម្រេចផលសិក្សាចុងឆ្នាំ និទ្ទេស A, B និង C | *ភាសាខ្មែរ* | 17 (2/5/10) | 24 (4/6/14) | | 40 (8/15/17) | 52 (12/20/20) |
| | | *គណិតវិទ្យា* | 17 (2/5/10) | 24 (4/6/14) | | 40 (8/15/17) | 52 (12/20/20) |

103

**របាយការណ៍កែចម្រើនការអនុវត្តផែនការកែលម្អសាលារៀនប្រចាំ ឆ្នាំ ២០២១**

**ឈ្មោះសាលារៀន៖** **លេខកូដ៖** **ឈ្មោះនាយកសាលា**

**លេខទូរស័ព្ទ៖** **ភូមិ៖** **ឃុំឬសង្កាត់**

**ក្រុង ស្រុក ខណ្ឌ៖** **រាជធានី ខេត្ត៖**

| សូចនាករសម្រេចបាននិងមិនបាន | សកម្មភាពបានអនុវត្តនិងមិនបានអនុវត្តក្នុងខែ | ឧបសគ្គ | ការរាំងស្ទាត់ | មិនមានសកម្មភាពជាដំណោះស្រាយ |
|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ |
| ស្តង់ដាទី១ សាលារៀនមានដំណើរការសម្រេចផលសម្រេចអប់រំនិងការសិក្សារបស់សិស្ស | | | | |
| ១ | សម្រេចបាន | មិនមាន | មិនមាន | ពិន្ទុ១ |
| *២* | *សម្រេចមិនបាន* | *?* | *?* | *ពិន្ទុ០* |
| ស្តង់ដាទី២៖ ថ្នាក់រៀនមានដំណើរការសម្រាប់ការបង្រៀននិងការសិក្សារបស់សិស្សម្នាក់ៗ | | | | |
| | | | | |

104

ស្តង់ដាទី៣៖ ភាពជាម្ចាស់របស់សហគមន៍សាលារៀន

ស្តង់ដាទី៤៖ ដំណើរការប្រតិបត្តិនិងរដ្ឋបាលសាលារៀន

ស្តង់ដាទី៥៖ គណនេយ្យភាពថ្នាក់ជាតិនិងក្រោមជាតិ

| | | | | |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |

*សម្គាល់៖ នាយកសាលាទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍នេះ ដោយមានការជួយពីនាយករងសាលារៀនទទួលបន្ទុកបច្ចេកទេសសម្រាប់បូកសរុបរបាយការណ៍ពីគ្រូទទួលបន្ទុកថ្នាក់ និងនាយករងសាលារៀនទទួលបន្ទុករដ្ឋបាលក្នុងការរៀបចំរបាយការណ៍ពីការរីកចម្រើមការអនុវត្តផែនការកែលម្អសាលារៀន។ ចំពោះសូចនាករមិនបានសម្រេច និងសកម្មភាពមិនបានអនុវត្ត ត្រូវដាក់ពណ៌ក្រហម និងធ្វើជាអក្សរផ្តេក។*

*ក្រោយពីការបញ្ចប់សារសេររបាយការណ៍រីកចម្រើនខាងលើហើយ នាយកសាលា នាយករងសាលារៀន គ្រូបង្រៀន និងក្រុមប្រឹក្សាយុវជនត្រូវពិភាក្សាកំណត់ពិន្ទុតាមគ្រប់ស្តង់ដានិងសូចនាករសម្រាប់ចុងចប់នៃឆ្នាំទី១ និងកំណត់ពិន្ទុស្តង់ដានិងសូចនាកសម្រាប់ផែនការឆ្នាំបន្ទាប់ដូចមានក្នុងតារាងខាងក្រោម។*



គំរូផែនការកែលម្អសាលារៀន និងថវិកា

ឈ្មោះសាលារៀន៖ លេខកូដ៖ ឈ្មោះនាយកសាលា៖

លេខទូរស័ព្ទ៖ ភូមិ៖ ឃុំឬសង្កាត់

ក្រុង ស្រុក ខណ្ឌ៖ រាជធានី ខេត្ត៖

តារាងពិន្ទុស្តង់ដាសហគមន៍សាលារៀន តាមស្តង់ដានីមួយៗ និងស្តង់ដាសរុប

| | ស្តង់ដាទី១ | | ស្តង់ដាទី២ | | ស្តង់ដាទី៣ | | ស្តង់ដាទី៤ | | ស្តង់ដាទី៥ | | សរុបពិន្ទុ | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ពិន្ទុអប្បបរមា | ៣៩ | | ៤៨ | | ៤៩ | | ៤៨ | | ២៧ | | ២១០ | |
| | ដើមឆ្នាំ | ចុងឆ្នាំ | ដើមឆ្នាំ | ចុងឆ្នាំ | ដើមឆ្នាំ | ចុងឆ្នាំ | ដើមឆ្នាំ | ចុងឆ្នាំ | ដើមឆ្នាំ | ចុងឆ្នាំ | ដើមឆ្នាំ | ចុងឆ្នាំ |
| ពិន្ទុឆ្នាំ ២០២១ | 0 | 13 | 0 | 14 | 0 | 16 | 0 | 16 | 0 | 9 | 0 | 70 |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ពិន្ទុឆ្នាំ ២០២២ | | | | | | | | | | | | |
| ពិន្ទុឆ្នាំ ២០២៣ | | | | | | | | | | | | |
| ពិន្ទុឆ្នាំ ២០២៤ | | | | | | | | | | | | |
| ពិន្ទុឆ្នាំ ២០២៥ | | | | | | | | | | | | |
| ពិន្ទុឆ្នាំ ២០២៦ | | | | | | | | | | | | |

*សម្គាល់៖ តារាងនេះមានពិន្ទុលម្អិតតាមស្តង់ដានីមួយៗ។ នៅចុងឆ្នាំសិក្សានីមួយៗ សូចនាករនីមួយៗត្រូវតែបានវាយតម្លៃ និងកំណត់ពិន្ទុ ហើយសរុបពិន្ទុសូចនាករទាំងអស់តាមស្តង់ដានីមួយៗ រួចសរសេរបញ្ចូលក្នុងតារាង។ ប្រើពណ៌បៃតងចំពោះស្តង់ដាណាដែលសម្រេចបានតាមពិន្ទុគោលគ្រោង និងប្រើពណ៌ក្រហមសម្រាប់ស្តង់ដាណាដែលសម្រេចមិនបានតាមពិន្ទុគ្រោង។ ពិន្ទុចុងឆ្នាំសិក្សាត្រូវបានយកទៅប្រើប្រាស់ជាតួលេខមូលដ្ឋានសម្រាប់ឆ្នាំសិក្សាបន្ទាប់។ ពិន្ទុចុងឆ្នាំមុនត្រូវចំឡងមកជាពិន្ទុដើមឆ្នាំបន្ទាប់។ រួចហើយត្រូវបញ្ចូលតារាងផែនការកែលម្អសាលារៀនសម្រាប់ផែនការឆ្នាំបន្ទាប់។*

107

**កំណត់ហេតុប្រជុំចុងឆ្នាំ២០២៣**
**ថ្ងៃ ខែ ឆ្នាំ ២០២៣**

**ប្រធានបទប្រជុំ**

១. របាយការណ៍ពីការរីកចម្រើនក្រុមគោលដៅលទ្ធផលសិក្សារបស់សិស្សនៅក្នុងឆ្នាំកន្លងមក

២. ពិភាក្សាពីបញ្ហា ឧបសគ្គ ការរាំងស្ទះ និង សកម្មភាពដោះស្រាយ

៣. ពិភាក្សាពីសកម្មភាពគ្រោងនៅឆ្នាំបន្ទាប់ ពិសេសផ្តោតលើការបង្កើនលទ្ធផលសិក្សា ពីសាលារៀនមានស្តង់ដា

**ការសម្រេចចិត្ត**

១. ការអនុវត្តសកម្មភាពជាដំណោះស្រាយបញ្ហាក្នុងឆ្នាំកន្លងមក
   ក.
   ខ.
   គ.

២. ការគ្រោងផែនការ និងសកម្មភាពផ្សេងៗនៅឆ្នាំបន្ទាប់
   ក.
   ខ.
   គ.

ហត្ថលេខាគណៈកម្មការគ្រប់គ្រងសាលារៀន ហត្ថលេខានាយកសាលារៀន

108

# របាយការណ៍សង្ខេបពីការដឹកនាំ

## *ជារបាយការណ៍ពីចំណេះដឹង*

## *ជួយដល់ការសម្រេចចិត្ត*

109

ឃ១-សរុបរបាយការណ៍ពីការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន ប្រចាំឆ្នាំ២០២១

**១) នាពរីកចម្រើនការអនុវត្តចក្ខុវិស័យសហគមន៍សាលារៀន**

វត្ថុបំណងនៃការរីកចម្រើនការអនុវត្តចក្ខុវិស័យសហគមន៍សាលារៀនគឺសិក្សាពីសំណួរថាតើសកម្មភាព ដែលត្រូវអនុវត្តបានអនុវត្តដែរឬទេ។ សកម្មភាពដែលត្រូវអនុវត្តមាន បេសកកម្ម និងគោលបំណង យុទ្ធសាស្ត្រនិងការផ្លាស់ប្តូរ និង វប្បធម៌ និងគុណតម្លៃសហគមន៍សាលារៀន។

ក) តើអ្វីដែលត្រូវធ្វើបានធ្វើដែរឬទេ ហើយតើអ្វីដែលត្រូវធ្វើតែមិនបានធ្វើ

ខ) បង្ហាញពីការផ្លាស់ប្តូរដែលទទួលបានទាក់ទងនឹង បេសកកម្មនិងគោលបំណង យុទ្ធសាស្ត្រ និងការផ្លាស់ប្តូរ និង វប្បធម៌ និងគុណតម្លៃសហគមន៍សាលារៀន

110

**២) នាទីកែចម្រើនការអនុវត្តស្តង់ដាសហគមន៍សាលារៀន**

វត្ថុបំណងនៃការអនុវត្តស្តង់ដាសហគមន៍សាលារៀនគឺ សិក្សាពីសំណួរថា តើអ្វីដែលបានធ្វើ តើធ្វើបានត្រឹមត្រូវដែរឬទេ។ ភាពត្រូវត្រូវនៃការអនុវត្តគឺ ត្រូវស្តែងចេញថាមានប្រសិទ្ធភាព (បំពេញបាននូវស្តង់ដាសហគមន៍សាលារៀន) ថាមានប្រសិទ្ធផល (ការជួយដល់សហគមន៍សាលារៀនដទៃទៀត) និង ការចូលចិត្តរបស់អតិថិជនគ្រប់ប្រភេទ។

ក) ការបំពេញបាននូវក្រុមគោលដៅស្តង់ដា និងសូចនាករសហគមន៍សាលារៀន

ខ) បរិមាណ និងគុណភាពនៃការជួយដល់សហគមន៍សាលារៀនផ្សេងទៀត ទាំងសាលាមធ្យមសិក្សា បឋមសិក្សា និងមត្តេយ្យសិក្សា

គ) ការចូលចិត្តរបស់អតិថិជន មានសិស្ស និងមាតាបិតាសិស្ស សហគមន៍ គ.គ.ស.ឬក.ប.ស. គ្រូបង្រៀន នាយក និងនាយករងសាលារៀន វិស័យពាក់ព័ន្ធ

111

**៣) មេរៀនពិសោធន៍ពីការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន**

វត្ថុបំណងនៃការស្វែងរកមេរៀនពិសោធន៍ពីការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន គឺ ការសិក្សាពីសំណួរថា តើមានអ្វីផ្សេងទៀតជាជម្រើសក្រៅពីកិច្ចការដែលត្រូវធ្វើទាំងនេះឬទេ ហើយតើមានជម្រើសណាមួយដែលល្អប្រសើរបំផុតនោះ និងថាតើមានអ្វីដែលប្រាកដនាំទៅរកនិរន្តភាពសហគមន៍សាលារៀនឬទេ។

ក) តើមានអ្វីផ្សេងទៀតជាជម្រើសក្រៅពីកិច្ចការដែលត្រូវធ្វើទាំងនេះឬទេ

ខ) ហើយតើមានជម្រើសណាមួយដែលល្អប្រសើរបំផុតនោះ

គ) ថាតើមានអ្វីដែលប្រាកដនាំទៅរកនិរន្តភាពសហគមន៍សាលារៀនឬទេ។

112

**៤) ចំណោទ និងសកម្មភាពដោះស្រាយ**

វត្ថុបំណងនៃការស្វែងរកចំណោទគឺ ការសិក្សាពីសំណួរដែលថា តើនៅមានឧបសគ្គនិងការរាំងស្កាត់អ្វីទៀតដែលនាំមិនឱ្យសម្រេចបាននូវផលសម្រេចគ្រោងទុក ហើយតើមានអ្វីជាពិសេសដោះស្រាយនូវការរាំងស្កាត់ទាំងនេះ និងថាតើអាទិភាពសកម្មភាពអ្វីដែលត្រូវផ្តោតសម្រាប់បញ្ចូលក្នុងផែនការកែលម្អសាលារៀន នៅឆ្នាំ បន្ទាប់។

ក) តើនៅមានឧបសគ្គនិងការរាំងស្កាត់អ្វីទៀតដែលនាំមិនឱ្យសម្រេចបាននូវផលសម្រេចគ្រោងទុក
ខ) ហើយតើមានអ្វីជាពិសេសដោះស្រាយនូវការរាំងស្កាត់ទាំងនេះ
គ) ថាតើអាទិភាពសកម្មភាពអ្វី ឬកម្មវិធីវិនិយោគអ្វីដែលត្រូវផ្តោតសម្រាប់បញ្ចូលក្នុងផែនការកែលម្អសាលារៀន នៅឆ្នាំបន្ទាប់។

113

**ខ) ការផ្សព្វផ្សាយពីការពិនិត្យឡើងវិញកម្រិតសាលារៀនជាមួយសហគមន៍**

វត្ថុបំណងនៃការអនុវត្តការពិនិត្យឡើងវិញកម្រិតសាលារៀននេះ គឺ ដើម្បីផ្តល់ព័ត៌មានដល់សហគមន៍ទាំងមូលពីភាពរីកចម្រើនលើផលសម្រេចអប់រំនិងការសិក្សារៀនសូត្ររបស់សិស្ស ឧបសគ្គ និងការរាំងស្កាត់ដែលនៅសេសសល់ និងអាទិភាពសកម្មភាពឬកម្មវិធីវិនិយោគដែលសាលារៀននឹងត្រូវផ្តោតសម្រាប់ឆ្នាំសិក្សាបន្ទាប់ ព្រមជាមួយនូវការសាកសួរពីសហគមន៍ទាំងមូល នូវការយល់ឃើញរបស់គេការចាប់អារម្មណ៍និងការស្វែងយល់របស់គេ និងការសម្រេចចិត្តជួយដល់សហគមន៍សាលារៀននៅឆ្នាំបន្ទាប់។

ពេលវេលាប្រជុំគឺនៅចុងខែធ្នូរៀងរាល់ឆ្នាំ។ ថ្នាក់ក្រោមជាតិ ឬថ្នាក់ជាតិអាចចូលរួម។

114

**គ- ការបិទផ្សាយទិន្នន័យលទ្ធផលសិក្សាចុងឆ្នាំជាសាធារណៈ**

នាយកសាលាដាក់ស្នើគ្រប់តារាងកម្រិតសាលារៀនដែលមាននៅខាងលើ ទៅគ.គ.ស.ឬក.ប.ស. សម្រេចអនុម័ត រួចហើយយកតារាងទាំងអស់នេះទៅបិទផ្សាយជាសាធារណៈ។

ដោយឡែកសម្រាប់កាតរបាយការណ៍សាលារៀន ក្រសួងនឹងបូកសរុបទិន្នន័យទទួលបានពីសាលារៀន រួច ផលិត និងបញ្ជូនកាតរបាយការណ៍សាលារៀនមកសាលារៀនវិញ ដើម្បីបិទផ្សាយជាសាធារណៈ។ គំរូកាតរបាយការណ៍សាលារៀនមានដូចខាងក្រោម។

115

## *ប្រភេទទិន្នន័យត្រូវបិទផ្សាយជាសាធារណៈ*

១. លទ្ធផលអប់រំជា ផ្ទេរការសិក្សា បោះបង់ការសិក្សា និងឡើងថ្នាក់ប្រចាំឆ្នាំ និងលទ្ធផលសិក្សារបស់សិស្សតាមមុខវិជ្ជាប្រចាំខែ ត្រីមាស និងឆ្នាំ
២. ចំណូល និងចំណាយ លុយរបស់សាលារៀន ប្រចាំឆ្នាំ
៣. ពិន្ទុស្តង់ដាសហគមន៍សាលារៀន ប្រចាំឆ្នាំ
៤. របាយការណ៍ឆ្នាំពីការរីកចម្រើនការអនុវត្តផែនការសហគមន៍សាលារៀន
៥. កាតរបាយការណ៍សាលារៀន

116

# ការអនុវត្តការគ្រប់គ្រងការអនុវត្តការងាររបស់នាយកសាលារៀននិងគ្រូបង្រៀន

117

***៣) ការអនុវត្តការគ្រប់គ្រងការអនុវត្តការងារគ្រូបង្រៀននិងនាយកសាលា***

**ក-ការអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់គ្រូបង្រៀននិងនាយកសាលា**

ឆ្នាំទី២នៃការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន គឺជាឆ្នាំដែលត្រូវចាប់អនុវត្តការគ្រប់គ្រងការអនុវត្តការងារគ្រូបង្រៀននិងនាយកសាលា។ ព្រោះក្រោយពីការអនុវត្តកិច្ចការនៅឆ្នាំទី១ហើយ គ្រូបង្រៀននិងនាយកសាលាអាចក្លាយជាមនុស្សថ្មី ដែលមានជំហរជួយសិស្សឱ្យរៀនសូត្របាន និងចាប់ផ្តើមយល់ពីកម្រិតសមត្ថភាពរបស់ខ្លួនដែលនៅខ្វះខាត និងសមត្ថភាពដែលត្រូវមានសម្រាប់ជួយសិស្ស។

118

**ខ-វត្ថុបំណងនិងការទទួលខុសត្រូវ**

- កម្មវិធីកំណែទម្រង់មានបំណងធ្វើឱ្យមានវឌ្ឍនភាព ដូចនេះការងារត្រូវធ្វើតាមរបៀបថ្មី
- អ្នកដឹកនាំទទួលខុសត្រូវចំពោះតម្រូវការរបស់មន្ត្រី ដូចនេះអ្នកដឹកនាំត្រូវជួយមន្ត្រីបំពេញសមត្ថភាពដែលនៅខ្វះចន្លោះ ដើម្បីធ្វើការងារតាមរបៀបថ្មី
- អ្នកដឹកនាំត្រូវរក្សាថាមពលធ្វើការងាររបស់មន្ត្រី ដូចនេះអ្នកដឹកនាំធានានូវការរក្សាគុណតម្លៃការងាររបស់មន្ត្រីដោយមិនមានភាពលម្អៀងផ្អែកលើលទ្ធផលការងារ
- អ្នកដឹកនាំមិនមានបំណងស្វែងរកកំហុសរបស់មន្ត្រីទេ តែមានបំណងផ្តល់ឱកាសឱ្យមន្ត្រីអភិវឌ្ឍខ្លួន និងបង្កើននូវការទទួលស្គាល់តម្លៃការងាររបស់មន្ត្រី

119

| ស្តង់ដាសហគមន៍សាលារៀន | អ្នកទទួលខុសត្រូវ |
|---|---|
| ស្តង់ដាទី១ សាលារៀនមានដំណើរការសម្រាប់ផលសម្រេចអប់រំនិងការរៀនសូត្រ | នាយកសាលា និងគ្រូបង្រៀន |
| ស្តង់ដាទី២ ថ្នាក់រៀនមានដំណោះរការសម្រាប់ការសិក្សាសិស្សម្នាក់ៗ | គ្រូបង្រៀន |
| ស្តង់ដាទី៣ សហគមន៍ជាម្ចាស់សហគមន៍សាលារៀន | នាយកសាលា |
| ស្តង់ដាទី៤ ដំណើរការរដ្ឋបាល និងការគ្រប់គ្រងសាលារៀន | នាយកសាលា |
| ស្តង់ដាទី៥ គណណេយ្យភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | នាយកសាលា |

120

**ឌ-ការផ្តល់ពិន្ទុ និងលទ្ធភាពផ្តល់រង្វាន់**

| លទ្ធផល | កម្រិតពិន្ទុ |
|---|---|
| សម្រេចផលសម្រេច គ្រប់លទ្ធផលគ្រោង និងលើសផែនការ | ៥ |
| សម្រេចគ្រប់លទ្ធផលគ្រោងទាំងអស់ | ៤ |
| សម្រេចលើ៦០% ដល់ ៨៥%នៃលទ្ធផលគ្រោង | ៣ |
| សម្រេចពី៥០% ទៅ ៦០%នៃលទ្ធផលគ្រោង | ២ |
| សម្រេចទាបជាង៥០% នៃលទ្ធផលគ្រោង | ១ |

*សម្គាល់៖*

- *មន្ត្រីមានពិន្ទុ១ឬ២មិនបង្ហាញគុណនេយ្យភាពឡើយ ផ្តល់ឱកាសឱ្យ១ឆ្នាំបន្ត បើមិនមានការកែលម្អទេ ត្រូវស្នើទៅសាកលវិទ្យាធិការមានវិធានការណ៍រដ្ឋបាល*
- *មន្ត្រីមានពិន្ទុ៣ ផ្តល់ឱកាស២ឆ្នាំសម្រាប់កែលម្អ និងឱកាសរៀនសូត្រ*
- *មន្ត្រីមានពិន្ទុ៤ ជាកម្រិតដែលអាចទទួលរង្វាន់កម្រិតមធ្យម តែមន្ត្រីមានពិន្ទុ៥ ជាមន្ត្រីឆ្នើម ត្រូវទទួលរង្វាន់ដែលប្រសើរ*

121

**កម្រិតសាលារៀន ដែលបំពេញស្តង់ដា ដំឡើងថ្នាក់:**




122

*លំហូរការងារ ក្នុងខែឆ្នូះ*

*១. នាយកសាលានិងគ្រូបង្រៀនពិភាក្សាលើកិច្ចព្រមព្រៀងលទ្ធផលឆ្នាំ*

123

*លំហូរការងារ ក្នុងខែឆ្នូះ*

*១. នាយកសាលានិងគ្រូបង្រៀនពិភាក្សាលើកិច្ចព្រមព្រៀងលទ្ធផលឆ្នាំ*

*២. នាយកសាលា និងគ្រូបង្រៀនពិភាក្សាលើការវាយតម្លៃពាក់កណ្តាលឆ្នាំ*

124

**លំហូរការងារ ក្នុងខែធ្នូ៖**

១. នាយកសាលានិងគ្រូបង្រៀនពិភាក្សាលើកិច្ចព្រមព្រៀងលទ្ធផលឆ្នាំ
២. នាយកសាលា និងគ្រូបង្រៀនពិភាក្សាលើការវាយតម្លៃ ពាក់កណ្តាាលឆ្នាំ
៣. នាយកសាលា និងគ្រូបង្រៀនពិភាក្សានិងឯកភាពលើឯកសារវាយតម្លៃឆ្នាំ

125

**លំហូរការងារ ក្នុងខែធ្នូ៖**

១. នាយកសាលានិងគ្រូបង្រៀនពិភាក្សាលើកិច្ចព្រមព្រៀងលទ្ធផលឆ្នាំ
២. នាយកសាលា និងគ្រូបនង្រៀពិភាក្សាលើការវាយតម្លៃ ពាក់កណ្តាលឆ្នាំ
៣. នាយកសាលា និងគ្រូបង្រៀនពិភាក្សានិងឯកភាពលើឯកសារវាយតម្លៃឆ្នាំ
៤. នាយកសាលារៀនបញ្ជូនឯកសារវាយតម្លៃមក គគស ស្នើសុំអនុម័ត
លទ្ធផលវាយតម្លៃឆ្នាំ និងការសុំស្នើឡើងឋានៈវិជ្ជាជីវៈ

126

### លំហូរការងារ ក្នុងខែធ្នូ៖

១. នាយកសាលានិងគ្រូបង្រៀនពិភាក្សាលើកិច្ចព្រមព្រៀងលទ្ធផលឆ្នាំ
២. នាយកសាលា និងគ្រូបង្រៀនពិភាក្សាលើការវាយតម្លៃ ពាក់កណ្ដាលឆ្នាំ
៣. នាយកសាលា និងគ្រូបង្រៀនពិភាក្សានិងឯកភាពលើឯកសារវាយតម្លៃឆ្នាំ
៤. នាយកសាលារៀនបញ្ជូនឯកសារវាយតម្លៃមក គគស ស្នើសុំអនុម័ត លទ្ធផលវាយតម្លៃឆ្នាំ និងការសុំស្នើឡើងឋានៈវិជ្ជាជីវៈ
៥. នាយកសាលារៀនបញ្ជូនឯកសារវាយតម្លៃមកក្រសួង ដើម្បីក្រសួងបូកសរុបស្នើសុំឋានៈវិជ្ជាជីវៈ ហើយក្រសួងនឹងបញ្ជូនព័ត៌មានមកសាលារៀនវិញពីលទ្ធផលនៃការសម្រេចចិត្ត។

127

❑ មនុស្សចេះដឹង ទទួលខុសត្រូវដោយ

និយាយការពិត និងបើកចំហការកុហក

និងប្រើចំណេះដឹងក្នុងសកម្មភាពការងារ និងជីវិតដើម្បី

ជួយដល់មនុស្សជុំវិញ និងសង្គម នោះទើបហៅថាមនុស្សចេះដឹង!!!

128

# ការពិនិត្យតាមដាន និងវាយតម្លៃ គម្រោង

## សេចក្តីផ្តើម

- ស្ថាប័ននានានៅទូទាំងពិភពលោកពឹងផ្អែកលើការពិនិត្យតាមដាន និងវាយតម្លៃដើម្បីវាស់ស្ទង់ភាពជោគជ័យ ដំណើរការ និងប្រតិបត្តិការរបស់ខ្លួន។
- ការពិនិត្យតាមដាន និងវាយតម្លៃ (M&E) គឺជាផ្នែកដ៏សំខាន់មួយនៃគម្រោងជោគជ័យ។ វា គឺ ជា វិធី មួយ នៃ ការតាមដាន ការរីកចម្រើន ដែលធានា ថា សកម្មភាពកំពុងដំណើរ ការ តាមដាន និង ធ្វើឱ្យប្រាកដ ថា ធនធានត្រូវ បានប្រើប្រាស់ ដោយមានប្រសិទ្ធិភាព ។

## តើអ្វីទៅជាការពិនិត្យតាមដាន និងវាយតម្លៃគម្រោង?

- ការពិនិត្យតាមដាន និងវាយតម្លៃគម្រោងត្រូវបានប្រើប្រាស់ដើម្បីវាស់ស្ទង់វឌ្ឍនភាពនៃគម្រោង។



## ហេតុអ្វីបានជាការពិនិត្យតាមដាន និង វាយតម្លៃ មានសារៈសំខាន់ នៅក្នុងគម្រោង?

- ការពិនិត្យតាមដាន និងវាយតម្លៃ ផ្តល់ទិន្នន័យចាំបាច់ ដើម្បីចង្អុលបង្ហាញអំពីការធ្វើផែនការយុទ្ធសាស្ត្រ ការរៀបចំ និងអនុវត្តកម្មវិធីនានា គម្រោងនានា និងធ្វើការសម្រេចចិត្តក្នុងការបែងចែកធនធានឱ្យបានត្រឹមត្រូវ។



## ហេតុផលចំនួន១០
## ដែលធ្វើឱ្យការពិនិត្យតាមដាននិងវាយតម្លៃមានសារៈសំខាន់




## ទី១

M&E ធ្វើឱ្យមានតម្លាភាព និងគណនេយ្យភាពកាន់តែប្រសើរ



## ទី២

M&E ជួយ ឱ្យអង្គភាព ដោះស្រាយបញ្ហានានា បានលឿន និងទាន់ពេលវេលា




## ទី៣

M&E ជួយក្នុងការធានាថា ធនធាន ប្រើប្រាស់ដោយមានប្រសិទ្ធភាព



## ទី៤

M&E ជួយអង្គភាព បានរៀនពីកំហុសរបស់ខ្លួន




## ទី៥

M&E ជួយធ្វើឱ្យការសម្រេចចិត្ត កាន់តែប្រសើរ



## ទី៦

M&E ជួយអង្គភាពដំណើរការ មានរបៀបរៀបរយ




## ទី ៧

M&E ជួយឱ្យអង្គភាពមួយ យកគំរូអង្គភាពមួយទៀតដែលល្អជាង ក្នុងការអនុវត្តគម្រោង /កម្មវិធី



## ទី៨

M&E លើកទឹកចិត្តក្នុងការធ្វើឱ្យមាននវានុវត្តន៍



## ទី៩

M&E លើកទឹកចិត្តឱ្យមានគំនិត និងមតិផ្សេងៗ




ទី១០
គ្រប់អង្គភាពបានប្រយោជន៍ពី M&E
Project/programme
monitoring and evaluation
(M&E) guide


ខួបនៃការពិនិត្យតាមដាន និងវាយតម្លៃគម្រោង
ទំហំនៃការវាយតម្លៃ
ថវិកា
ពេលវេលា
លទ្ធផល
ការវាយតម្លៃ
ផលជះ
វិជ្ជមាន
អវិជ្ជមាន

# តើយុទ្ធសាស្ត្រ M&E ជោគជ័យមានអ្វីខ្លះ?

## ស្គាល់ គម្រោងរបស់អ្នកទាំងផ្ទៃក្នុង និង ខាងក្រៅ

- យល់ពីគោលដៅគម្រោង គោលបំណង កំណត់គោលដៅ អ្នកទទួលផលពីគម្រោង ថវិកា និងធនធានដែលមាន។ នេះ បង្កើតជាមូលដ្ឋានសម្រាប់ M&E។

M&E

## ចាប់ផ្តើមរៀបចំផែនការ M&E ក្នុងអំឡុងពេលរៀបចំគម្រោង

- ភ្ជាប់ M&E ទៅ នឹងផែនការយុទ្ធសាស្ត្រ របស់គម្រោងចាប់តាំង ពីដើមមក។ កំណត់ អត្តសញ្ញាណ តម្លៃ មូលដ្ឋាន និង បញ្ចូល M&E ជាមួយគម្រោង

## ធ្វើ ឱ្យ M&E ដំណើរការរហូត

- ជៀសវាងការដាក់ចេញនូវវិធីសាស្ត្រហួសសម័យនៃការអនុវត្តM&Eតែនៅដំណាក់កាលចុងក្រោយនៃគម្រោង បញ្ចូលវា ប៉ារ៉ាឡែល ទៅនឹងការធ្វើអន្តរាគមន៍ គម្រោងសម្រាប់ទិដ្ឋភាពទូលំទូលាយ។

## ស្វែងយល់ពីឧបករណ៍ M&E និង Methodologies ផ្សេងៗ

- ជ្រើសឧបករណ៍ ដែលសមស្រប នឹងវិសាលភាពគម្រោងរបស់អ្នក ។ សូមពិចារណា អំពីប្រភេទគម្រោង និងដំណាក់កាលរបស់វា។

## រៀបចំ សូចនាករដែលមានការទាក់ទងគ្នានឹងគម្រោង

- កំណត់សម្គាល់ជាក់លាក់ ដែលអាចវាស់បាននៃវឌ្ឍនភាពឬសមិទ្ធផល។

## ប្រមូលទិន្នន័យដែលមានគុណភាពពីប្រភពច្រើន

- ធានាភាពត្រឹមត្រូវ នៃទិន្នន័យ ដោយប្រើវិធីសាស្ត្រ ប្រមូលដែលអាចទុកចិត្តបាន

## សហការបំពេញការងារ

- បំពេញការងារជាក្រុម ជាសហគមន៍ និងអ្នកពាក់ព័ន្ធទាំងអស់ក្នុង ដំណើរការ M&E

## ផ្សព្វផ្សាយលទ្ធផល ជាប្រចាំ ដល់មហាជនឱ្យបានទូលំទូលាយ

- ចែករំលែកការរកឃើញ និងជូនដំណឹងដល់អ្នកសម្រេចចិត្ត និងអំពីភាពប្រសើរឡើងនៃលទ្ធផលគម្រោង

## ត្រូវចងចាំថា ជោគជ័យ M&E តម្រូវឱ្យមានការសម្របខ្លួន និងរៀនបន្ត!

## ហេតុអ្វីបានជាគម្រោងខ្លះបរាជ័យ ?

## ទី១- វត្ថុបំណងរបស់គម្រោងមិនច្បាស់លាស់


ទី២-វិសាលភាពគ្រោងធំពេក


ទី៣- ការរំពឹងទុកមិនពិតប្រាកដ


ទី៤- ធនធាន មានកម្រិត


ទី៥- ទំនាក់ទំនងមិនល្អ


ទី៦- ការពន្យារពេលវេលា


ទី៧- ខ្វះតម្លាភាព


ទី៨- ខ្សោយក្នុងភាពជាអ្នកដឹកនាំ


ទី៩- តួនាទី និងភារកិច្ចមិនច្បាស់លាស់


ទី១០- គ្មានភាពបត់បែនដើម្បីផ្លាស់ប្តូរ


ទី១១- ការប៉ាន់ស្មាន តម្លៃ មិនត្រឹមត្រូវ

## តើអ្វីជាបញ្ហាប្រឈមនៃការពិនិត្យតាមដាន និងវាយតម្លៃ ?

## ទិន្នន័យត្រឹមត្រូវ

- ទិន្នន័យមិនត្រឹមត្រូវវាជាឧបសគ្គក្នុងកិច្ចខិតខំប្រឹងប្រែងរបស់M&E។ ដើម្បីដោះស្រាយបញ្ហានេះ ត្រូវតែកាត់បន្ថយទិន្នន័យ មិនត្រឹមត្រូវជាអតិប្បរមា និងរក្សាទុកតែទិន្នន័យត្រឹមត្រូវ

## ការផ្លាស់ប្តូរផ្នត់គំនិត

- មនុស្សមួយចំនួនអាចមានការសង្ស័យ អំពីវិធីសាស្ត្រវាស់វែង និង ការវាយតម្លៃ ។ ពន្យល់អ្នកពាក់ព័ន្ធអំពីអត្ថប្រយោជន៍របស់ M&E ដោយសង្កត់ធ្ងន់លើវិធីសាស្ត្រដែលពិចារណាអំពីភាពមិនច្បាស់លាស់ និងមិនរំពឹងទុក។

## ការប្រមូលទិន្នន័យ

- ការប្រមូលទិន្នន័យដែលពាក់ព័ន្ធអាចជាការលំបាក។


ធនធានមានកម្រិត
• ធនធានមានកម្រិត អាច ប៉ះពាល់ដល់ការប្រមូល ទិន្នន័យសំខាន់ របស់ M&E ។ ត្រូវធ្វើអាទិភាពទិន្នន័យដែលត្រូវប្រមូល និងផ្តោតតែលើសូចនាករសំខាន់ ៗ ។


បញ្ហា ស្ថិតិ មិនប្រាកដប្រជា
• ដោះស្រាយបញ្ហាស្ថិតិដោយប្រើប្រាស់វិធីសាស្ត្ររឹងមាំដែលទទួលខុសត្រូវចំពោះភាពមិនច្បាស់លាស់និងលទ្ធផលដែលមិននឹកស្មានដល់ទាំងនោះ។

## របាយការណ៍

- *ការសរសេរ របាយការណ៍ សំដៅ ទៅលើដំណើរការ នៃការ ផលិតឯកសារ មួយ បង្ហាញព័ត៌មានច្បាស់លាស់ ។ របាយការណ៍ អាចសរសេរសម្រាប់ គោលបំណងផ្សេងៗដូចជា ការផ្តល់នូវបច្ចុប្បន្នភាព លើគម្រោង ការវិភាគ ទិន្នន័យ ឬ ការបង្ហាញ នូវការរកឃើញ ឬ ការផ្តល់អនុសាសន៍នានា។*



## តើរបាយការណ៍ជាអ្វី?

- របាយការណ៍ គឺ ជារឿងនិទាន អំពីអ្វីដែលបានធ្វើ និងសំខាន់បំផុតនូវអ្វី ដែលបានរៀនពីការងាររបស់អ្នក ។ តែរឿងនិទាននោះមិនមែន ជាអ្វីដែល អ្នកប្រឌិតនោះទេ វាត្រូវតែផ្អែកលើភស្តុតាង ដែលបានប្រមូល ។

## អ្នកទទួលព័ត៌មាន

- របាយការណ៍ នេះ ត្រូវសរសេរសម្រាប់អត្ថប្រយោជន៍ដល់អ្នកដទៃ និង ផ្តល់ព័ត៌មាន ដល់ពួកគេអំពីអ្វីដែលបានកើតឡើង ។
- សំណួរទីមួយ ដែលអ្នកធ្វើរបាយការណ៍ត្រូវសួរ គឺតើនរណា នឹង ទទួលរបាយការណ៍នេះ ? ជាសហការី? មន្ត្រីជាន់ខ្ពស់? រដ្ឋមន្ត្រី អ្នកដែលចូលរួមកិច្ចប្រជុំពិសេសៗ ដូចជាសន្និបាតអប់រំ ម្ចាស់ជំនួយ ឬក៏ឪពុកម្តាយសិស្ស ។

## របៀបសរសេររបាយការណ៍

- ជាដំបូង យើងត្រូវដឹងពីពេលវេលាដែលត្រូវធ្វើរបាយការណ៍ ដូច្នេះយើងអាចរៀបចំកាលវិភាគធ្វើការងាររបាយការណ៍នេះ។
- បន្ទាប់មកយើងអានរបាយការណ៍មុនៗ
- ប្រឹក្សាយោបល់ជាមួយអ្នកដែលសរសេររបាយការណ៍មុនៗ។ សុំយោបល់អ្នកទាំងនោះអំពីប្រភពទិន្នន័យដែលយើងត្រូវការ
- ប្រើបច្ចេកវិទ្យាដើម្បីជួយអ្នកក្នុងការកាត់ចម្លងកន្លែងណាដែលត្រូវការ។

## គួរចងចាំ

- ហេតុអ្វីបានជាតម្រូវឱ្យមានរបាយការណ៍?
- អ្នកត្រូវដឹងថា អ្នកណាខ្លះត្រូវការរបាយការណ៍
- តើទិន្នន័យអ្វីដែលត្រូវប្រមូល និងផ្ទៀងផ្ទាត់ទិន្នន័យបច្ចុប្បន្ន?
- តើមានត្រូវការទិន្នន័យថ្មីផ្សេងទៀត?
- តើទិន្នន័យទាំងនេះផ្សាភ្ជាប់ទៅនឹងសូចនាករ?
- ជំហានបន្ទាប់ជាជំហានវិភាគដែលជាផ្នែកមួយពិបាក ពីព្រោះអ្នកមិនត្រឹមតែមើលលើអ្វីដែលបានធ្វើទេ ប៉ុន្តែអ្នកត្រូវមើលថាតើមានអ្វីប្រែប្រួល ហើយការប្រែប្រួលនេះផ្សាភ្ជាប់ទៅនឹងការរំពឹងទុកយ៉ាងដូចម្ដេច។

## គួរចងចាំ

- ក្នុងរបាយការណ៍ត្រូវរៀបរាប់ពីវឌ្ឍនភាពដោយធៀបទៅនឹង៖
  - ឆ្នាំគោល
  - សូចនាករ
  - ចំណុចដៅតាមឆ្នាំ
- របាយការណ៍ត្រូវ ______
  - កំណត់អ្នកដែលទទួលផល
  - ឧបសគ្គដែលរារាំងការរីកចម្រើន និងបញ្ហាប្រឈម
  - ឱកាសដែលអាចមាន ឧត្តមានុវត្ត និងអានុសាសន៍

## គួរចងចាំ

- ពេល អ្នកសរសេររបាយការណ៍ អ្នកត្រូវតែច្បាស់ ថា អ្នកកំពុងសរសេរទៅនរណា?

- រាយការណ៍ជូនមហាជន រាយការណ៍ជូនចៅហ្វាយ នាយ រាយការណ៍ជូនមិត្តរួមការងារ

## បង្កើត Timetable

- អ្នកត្រូវដឹងថា តើរបាយការណ៍របស់អ្នកត្រូវការនៅពេលណា ដែលជាចំណុច ចាប់ផ្តើម ។ មិន គួរ ធ្វើរបាយការណ៍ក្នុងរយៈពេលតែ១យប់ មុនពេលកំណត់ នោះទេ ។ របាយការណ៍ ដែល ធ្វើក្នុងស្ថានភាពប្រញាប់ប្រញាល់ គឺជារបាយ ការណ៍មិនល្អ និង មិនគ្រប់ជ្រុងជ្រោយ ។

## ឧទាហរណ៍

| កាលបរិច្ឆេទ | ការងារត្រូវធ្វើ |
|---|---|
| 1st មករា | • សំណើសរសេររបាយការណ៍ ? របាយការណ៍សម្រាប់អ្នកណា ? គេចង់ដឹងអំពីអ្វី? |
| | • ការងារមួយចំនួនត្រូវធ្វើ |
| 2nd មករា | ✓ តើត្រូវការពត៌មានអ្វីខ្លះ? |
| 6th មករា | ✓ ត្រូវការទិន្នន័យបន្ថែមទៀតទេ? |
| 15th មករា | ✓ បានធ្វើអ្វីខ្លះហើយ? |
| 23rd មករា | ✓ សរសេរសេចក្តីព្រាង |
| 26th មករា | ✓ ត្រួតពិនិត្យពត៌មាន |
| 28th មករា | បញ្ចប់សេចក្តីព្រាង |
| 1st កុម្ភៈ | ពេលវេលាត្រូវបង្ហាញរបាយការណ៍ |

## សូមរៀបចំផែនការសរសេររបាយការណ៍របស់អ្នកនិងធ្វើការកំណត់អំពីអ្វីដែលត្រូវធ្វើ

- *សូមមើលរបាយការណ៍មុនៗ ឬ របាយការណ៍ស្រដៀងគ្នា ដែលបានសរសេរពីមុនមក ។*

- *ស្វែងរក អ្នកដែលបានសរសេររបាយការណ៍ពីមុន ហើយសួរដំបូន្មាន របស់ពួកគេ អំពីវិធីដ៏ល្អបំផុតដើម្បីសរសេរវា ។*

## សូមមើល របាយការណ៍ពីមុនៗ ដោយ មួតា មិន ចាំបាច់បង្កើត គម្ពីថ្មីទេ ប៉ុន្តែ អ្នកគ្រាន់តែ កាល ផ្លាស់ប្តូរ ដែល បានធ្វើ ពីមុនមក។

- បច្ចេកវិទ្យា៖ កម្មវិធីកុំព្យូទ័រ មានប្រយោជន៍ខ្លាំងណាស់ ប៉ុន្តែត្រូវប្រុងប្រយ័ត្ន។
- ប្រសិនបើអ្នក ' Cut និង Paste 'សូមប្រាកដថាអ្វីដែលបានជ្រើសគឺសមហេតុផល ហើយ ថាអ្នកបានផ្លាស់ប្តូរអ្វីៗ ដូចជា កាលបរិច្ឆេទ វេយ្យាករណ៍ ។ល។



## ប្រើបច្ចេកវិទ្យា ដើម្បី ជួយសរសេរ របាយការណ៍ អាជីព

- កម្មវិធីកុំព្យូទ័រនឹងរកឃើញកំហុសដែលអ្នកធ្វើដែរ។ ប្រសិនបើខុសអក្ខរាវិរុទ្ធ ឬពាក្យខុសវានឹងត្រូវបង្ហាញដោយ **<u>បន្ទាត់ក្រោមពណ៌ក្រហម</u>** ។ សូមកុំបដិសេធន៍ នឹងការកែរបស់ម៉ាស៊ីន វានឹងជួយធ្វើឱ្យរបាយការណ៍របស់អ្នកកាន់តែមានវិជ្ជាជីវៈ ។ ប្រសិនបើអក្ខរាវិរុទ្ធ ឬវេយ្យាករណ៍របស់អ្នកមិនត្រឹមត្រូវនោះវានឹងប្រាប់អ្នក។

- **តើអ្វីជាចំណុចសំខាន់បំផុតនៅពេលសរសេររបាយការណ៍?**
  - និយាយឱ្យខ្លីដើម្បីទទួលបានជោគជ័យ របាយការណ៍មួយត្រូវតែធានាថាអ្នកអាចឃើញភ្លាម អានភ្លាម មិនបង្អង់យូរ។ យល់ពីអ្វីៗទាំងអស់ក្នុងនោះដោយគ្មានការខិតខំច្រើន ទទួលយកការពិត, គំហើញ, សន្និដ្ឋាននិងអនុសាសន៍; និង សម្រេចចិត្ត ចាត់វិធានការ ដែលបានផ្តល់អនុសាសន៍ ។

# របាយការណ៍ខាយតម្លៃ

## គោលបំណងនៃរបាយការណ៍វាយតម្លៃ

- **គណនេយ្យភាព៖** ដើម្បីវាយតម្លៃថា តើកម្មវិធី ឬគម្រោងបានបំពេញគោលបំណងរបស់ខ្លួន និងបានផ្តល់លទ្ធផលដែរឬទេ? និងដើម្បីឱ្យ អ្នកពាក់ព័ន្ធទទួលខុសត្រូវចំពោះសកម្មភាព និង ការសម្រេចចិត្តរបស់ខ្លួន

## គោលបំណងនៃរបាយការណ៍វាយតម្លៃ

- **ការរៀនសូត្រ៖** ដើម្បីកំណត់អត្តសញ្ញាណមេរៀនសំខាន់ៗដែលរៀនពីកម្មវិធី ឬគម្រោង រួមមានការអនុវត្តល្អបំផុត ឧបសគ្គ និងឱកាសដើម្បីកែលម្អ និងអនុវត្តមេរៀនទាំងនេះទៅកម្មវិធី ឬគម្រោងនាពេលអនាគត។

## គោលបំណងនៃរបាយការណ៍វាយតម្លៃ

- **ការកែលម្អ៖** ដើម្បីផ្តល់អនុសាសន៍សម្រាប់កម្មវិធី ឬកែលម្អគម្រោងដោយផ្អែកលើការរកឃើញការវាយតម្លៃ និងការសន្និដ្ឋាន និងដើម្បីគាំទ្រការសម្រេចចិត្តដែលមានមូលដ្ឋានលើភស្តុតាង។

## គោលបំណងនៃរបាយការណ៍វាយតម្លៃ

- **ប្រាស្រ័យទាក់ទង៖** នេះជាទំនាក់ទំនងដើម្បីរកការវាយតម្លៃ និងការសន្និដ្ឋានមួយ ត្រូវទាក់ទងដល់អ្នកពាក់ព័ន្ធ រួមមានបុគ្គលិកកម្មវិធី អ្នកផ្តល់មូលនិធិ អ្នកតាក់តែងគោលនយោបាយ និងសាធារណជនទូទៅ ដើម្បីលើកកម្ពស់តម្លាភាព និងការចូលរួមរបស់ភាគីពាក់ព័ន្ធ។

## បញ្ហាប្រឈមនៃការសរសេររបាយការណ៍វាយតម្លៃ

- **ខ្វះទិន្នន័យ៖** ឧបសគ្គដ៏ធំបំផុតមួយក្នុងការសរសេរ របាយការណ៍វាយតម្លៃ គឺការដោះស្រាយការខ្វះទិន្នន័យ ។ អ្នកវាយតម្លៃ អាចរកឃើញថាទិន្នន័យ ដែលពួកគេប្រមូល គឺ មិនពេញលេញ មិនត្រឹមត្រូវ នាំឱ្យមានការលំបាកក្នុងការសន្និដ្ឋាន ។

## បញ្ហាប្រឈមនៃការសរសេររបាយការណ៍វាយតម្លៃ

- ការខ្វែងគំនិតគ្នារបស់អ្នកជាប់ពាក់ព័ន្ធ ៖ បញ្ហាប្រឈមទូទៅមួយទៀត គឺ ការខ្វែងគំនិតគ្នារបស់អ្នកជាប់ពាក់ព័ន្ធ លើការរកឃើញ និង អនុសាសន៍ របស់ការវាយតម្លៃ ។ អ្នកពាក់ព័ន្ធ អាចមានមតិខុសគ្នាអំពីប្រសិទ្ធភាពរបស់កម្មវិធីឬដំណើរការនៃសកម្មភាពដែលបានរកឃើញ។

## បញ្ហាប្រឈមនៃការសរសេររបាយការណ៍វាយតម្លៃ

- **ជំនាញ សរសេរ បច្ចេកទេស៖** អ្នកវាយតម្លៃអាចនឹងមាន ការលំបាកជាមួយនឹងជំនាញសរសេរបច្ចេកទេស ដែលជា ការចាំបាច់សម្រាប់បង្ហាញនូវការរកឃើញវាយតម្លៃ ដ៏ស្មុគស្មាញក្នុងរបៀបច្បាស់លាស់និងមានភាពស្មុគស្មាញ។ជំនាញសរសេរគឺមានសារៈសំខាន់ជាពិសេសនៅពេលបង្ហាញទិន្នន័យស្ថិតិឬព័ត៌មានបច្ចេកទេសផ្សេងទៀត ។

## បញ្ហាប្រឈមនៃការសរសេររបាយការណ៍វាយតម្លៃ

- **ពេលវេលាមានកំណត់ ៖** អ្នកវាយតម្លៃអាចប្រឈមមុខ នឹងពេលវេលាក្នុងការសរសេររបាយការណ៍វាយតម្លៃ ជា ពិសេស ប្រសិន បើរបាយការណ៍នេះត្រូវការយ៉ាងលឿន ឬ ការវាយតម្លៃបានតែពាក់ព័ន្ធ ជៀមនឹង ការប្រមូលទិន្នន័យ និងការវិភាគដ៏ច្រើន ។


បញ្ហាប្រឈមនៃការសរសេររបាយការណ៍វាយតម្លៃ
• របាំងទំនាក់ទំនង ៖ អ្នកវាយតម្លៃអាចជួបប្រទះឧបសគ្គ ទំនាក់ទំនងនៅពេលធ្វើការជាមួយអ្នកជាប់ពាក់ព័ន្ធដែល និយាយភាសាផ្សេងគ្នា ឬមានសាវតា វប្បធម៌ ផ្សេងៗគ្នា ។ ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពគឺមានសារៈសំខាន់ណាស់សម្រាប់ធានាថាការរកឃើញនៃការវាយតម្លៃត្រូវបានយល់និងធ្វើសកម្មភាព។

# បទបង្ហាញ ស្តីពី
# ក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃ
# ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ

1

